ខែ ធ្នូ ឆ្នាំ 2015
193

សូមចូលទៅកាន់គេហទំព័រ www.itcity.com.kh ដើម្បីទាញយកទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យាដោយឥតគិតថ្លៃ

ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម 010 67 67 67 / 018 9 333337

# ទស្សនាវដ្ដី ទីក្រុង ពត៌មានវិទ្យា

IT MAGAZINE

we live with technology

IT CITY MAGAZINE

វិធីសាស្ត្រ
**Sync Password Google Account**



ស្វែងយល់លក្ខណៈកុំព្យូទ័រ
**LG gram, HP Pavilion X2 Intel NUC, HP Envy Curved**

LG Gram

**មេរោគកុំព្យូទ័រ 8 ប្រភេទដែលត្រូវប្រុងប្រយ័ត្នបំផុត**

វិធីសាស្ត្រក្នុងការបិទ **pop-ups** នៅក្នុង **Browser**



បេសកកម្មសម្ងាត់ក្នុងពិភពសង្គ្រាម
**CALL OF DUTY BLACK OPS III**

Herbal Health

# ថ្នាំបំប៉ន
# ផ្សំឡើងដោយ
# រុក្ខជាតិធម្មជាតិ ១០០%

## Jointcare

**មានប្រសិទ្ធិភាពខ្ពស់ក្នុងការព្យាបាលៈ**

- ✓-រលាកសន្លាក់ឆ្អឹង
- ✓-ជម្ងឺប្រគ្រីវ
- ✓-កាត់បន្ថយការតានតឹង ខ្វល់ខ្វាយក្នុងអារម្មណ៍
- ✓-ការពារជម្ងឺកើតមុន និងរោគរលាកស្បែក
- ✓-រោគសន្លាក់ឆ្អឹងផ្សេងៗ




Herbal Health

ទីស្នាក់ការធំ រាជធានីភ្នំពេញ :
ផ្ទះលេខ 8AE0 ផ្លូវលេខ 156 សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ 023 67 68 711 / 088 8651111 / 016 555 889



DUAL USB
CAR CHARGER
30%
Discount
- Charge all iPhone and iPod models
- Charge all BlackBerry models
and other USB powered devices
in the car
- Blue LED light indicator
មានលក់នៅហាង Digital
#8AEo ផ្លូវលេខ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
Tel: 016 555 889, 023 555 6 777
Digital Cambodia
www.digital-cambodia.com




# ក្រុម Hacker របស់ Isis ត្រលប់មកវិញដើម្បីសងសឹក

នៅរដ្ឋអ៊ីស្លាម និងក្រុមសមយុទ្ធសេរ៊ីនៃប្រទេសអ៊ីរ៉ាក់ បានបង្ហាញថា Twitter ចំនួនរាប់ពាន់ account ត្រូវបាន Hack ជាមួយការបង្ហាញលេខទូរស័ព្ទសមាជិករបស់ CIA និង FBI ដើម្បីសងសឹកពីការសម្លាប់ក្រុម Hacker កំពូលរបស់ខ្លួន។

Twitter account ច្រើនជាង 54,000 រួមជាមួយ password ជាច្រើនត្រូវបានបង្ហោះដែលនេះជាសង្គ្រាមលើបណ្តាញក្នុងសាកលលោកយ៉ាងធំ។ ក្រុម Hacker មួយក្រុមដែលបង្កើតឡើងដោយសមាជិក ISIS ត្រូវបានគេហៅថា 'Cyber Caliphate' បានគ្រប់គ្រង Account ជាច្រើន និងបានប្រើ Account ទាំងនោះដើម្បីឃោសនា អ៊ីរ៉ាក់និងស៊ីរី នេះយោងតាមការរាយការណ៍ កាសែត Daily Express។ ជនរងគ្រោះ ត្រូវបានគេបង្ខំឱ្យមើលវោហាសាស្ត្រអំណាចរបស់ ISIS ដោយផុសចេញពី Account របស់អ្នករងគ្រោះទាំងនោះ។

ក្រុម Hacker ក៏បានផុសព័ត៌មានផ្ទាល់ខ្លួន រួមជាមួយលេខទូរស័ព្ទរបស់ក្រុម CIA និង FBI និងរបស់ក្រុមសន្តិសុខជាតិអាមេរិក National Security Agency (NSA) ក្នុងពេលតែមួយ។ ក្រោយពីសំលាប់ក្រុម Hacker កំពូលអស់ជាច្រើននាក់ពីបទ Hack លើ account របស់ Twitter Pentagon កាលពីដើមឆ្នាំ សកម្មភាពក្រុម Hacker ក៏មានសភាពស្ងប់ស្ងាត់ទៅវិញ ប៉ុន្តែក្រោយមកក្នុងសប្តាហ៍មុននេះក្រុមនេះបង្ហាញខ្លួនម្តងទៀតជាមួយឃ្លាថា"We are back."។ ក្រុមនេះក៏បានប្រើពាក្យចំអកជាច្រើនមុនពេលភ្ជាប់ Link ដើម្បីចូលទៅលួចទិន្នន័យ Twitter account។ ពួកគេបានលើកឡើងថា «យើងប្រើរយៈពេលមួយឆ្នាំដើម្បីផ្សព្វផ្សាយអ្វីដែលមានក្នុងដៃរបស់យើង ហើយយើងនឹងលើកទង់របស់ពួកយើងនៅចំកណ្តាលសហគមន៍អឺរ៉ុប» ៕



Diamond

# SECURITY CAMERA SET

## EN-6608V



- DVR 8 CH H.264 Network Stand Alone x 1
- Color IR Camera Outdoor (600TVL, 3.6MM) x 4
- Cable 18M BNC+DC Video x 4
- 1 to 4 Power Cable Splitter x 1
- USB Mouse x1
- IR Remote Controller x1
- DC 12V Power Supply Adapter x 1

## See your business from anywhere with internet

### SDV04K-CI30K-SDI



- 4CH HD-SDI CCTV Surveillance System DVR x 1
- HD-SDI Mega pixels Color Camera x 4
- 20M Wire BNC+DC Video Cable x 4
- 1 to 4 Power Splitter Cable x 1
- 4 TB SATA HDD x 1 (3 weeks store)
- USB Mouse x 1
- IR Remote Controller x 1
- DC12V Power Supply Adapter x 1

### EN-6868K SERIES



- 8CH H.264 with 15 inch LCD all-in one Network DVR x 1
- Color IR Camera x 8
- 18M BNC+DC Video Cable x 8
- 1 to 8 Power Cable Splitter x 1
- 1 TB SATA HDD x 1 (3 weeks store)
- USB Mouse x 1
- IR Remote Controller x 1
- DC12V Power Supply Adapter x 2

### EN-6704VK SERIES



- 8CH H.264 Network Stand Alone DVR x1
- Color IR Camera x 4
- 18M BNC+DC Video Cable x 4
- 1 to 4 Power Cable Splitter x 1
- 500GB SATA HDD x 1 (3 weeks store)
- USB Mouse x 1
- IR Remote Controller x 1
- DC12V Power Supply Adapter x 1

### EN-6708VK SERIES



- 8CH H.264 Network Stand Alone DVR x1
- Color IR Camera x 8
- 18M BNC+DC Video Cable x 8
- 1 to 8 Power Cable Splitter x 1
- 1 TB SATA HDD x 1 (3 weeks store)
- USB Mouse x 1
- IR Remote Controller x 1
- DC12V Power Supply Adapter x 2




## PCS+ R9 290X 8GB GDDR5

- Part NumberAXR9 290X 8GBD5-PPDHE
- Graphics EngineRADEON R9 290X
- Video Memory8GB GDDR5
- Engine Clock1030MHz
- Memory Clock1375MHz (5.5Gbps)
- Memory Interface512bit
- DirectX® Support12
- Bus StandardPCIE 3.0
- Display ConnectorsDL DVI-D/ DL DVI-D/ HDMI/



$ 599

## TurboDuo R9 290 4GB GDDR5 OC

- Part NumberAXR9 290 4GBD5-TDHE/OC
- Graphics Engine RADEON R9 290
- Video Memory4GB GDDR5
- Engine Clock975MHz
- Memory Interface512bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL DVI-D/DL DVI-D/HDMI/DP



$ 549

## TurboDuo R9 280X 3GB GDDR5 OC

- Part NumberAXR9 280X 3GBD5-T2DHE/OC
- Graphics Engine RADEON R9 280X
- Video Memory3GB GDDR5
- Memory Clock1500MHz x4 (6.0 Gbps)
- Memory Interface384bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI/HDMI/Mini Display Port x2



$ 399

## PCS+ R9 270X 2GB GDDR5

- Part NumberAXR9 270X 2GBD5-PPDHE
- Graphics Engine RADEON R9 270X
- Video Memory2GB GDDR5
- Memory Clock1425MHz (5.7Gbps)
- Memory Interface256bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI-I/DL-DVI-D/HDMI/Display



$ 299

## TurboDuo R9 270 2GB GDDR5 OC

- Part NumberAXR9 270 2GBD5-TDHE/OC
- Graphics EngineRADEON R9 270
- Video Memory2GB GDDR5
- Memory Clock1400MHz (5.6Gbps)
- Memory Interface256bit
- DirectX® Support11.2
- Bus StandardPCIE 3.0
- Display ConnectorsDL DVI-I/ HDMI/ DisplayPort



$ 250

## TurboDuo R7 265 2GB GDDR5 OC

- Part NumberAXR7 265 2GBD5-TDHE/OC
- Graphics Engine RADEON R7 265
- Video Memory2GB GDDR5
- Memory Clock1400MHz (5.6Gbps)
- Memory Interface256bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI-I/ HDMI/ Display Port



$ 199

## R7 250 1GB GDDR5 OC

- Part NumberAXR7 250 1GBD5-HV2E/OC
- Graphics Engine RADEON R7 250
- Video Memory1GB GDDR5
- Memory Clock1150MHz (4.6Gbps)
- Memory Interface128bit
- DirectX® Support11.2
- Bus Standard PCIE 3.0
- Display Connectors DL-DVI-D/HDMI/VGA



$ 135

## HD6450 1GB DDR3 HDMI

- Part NumberAX6450 1GBk3-SH
- Graphics EngineRADEON HD6450
- Video Memory1GB DDR3
- Engine Clock625MHz
- Memory Clock667Mhz x 2
- Memory Interface64bit
- DirectX® Support11
- Bus StandardPCIE 2.1
- Display ConnectorsDL DVI-D/ HDMI/ VGA



$ 60


ដើម្បីសុវត្ថិភាពលោកអ្នក
- កាមេរ៉ាចាប់យករូបភាពច្បាស់ល្អ
- អាចមើលតាមទូរសព្ទពីចម្ងាយ
- ដំឡើងដោយជាងជំនាញ
មានបទពិសោធន៍ច្រើនឆ្នាំ
- ទទួលដំឡើងគ្រប់ខេត្ត ក្រុង
- តម្លៃថោកសមរម្យ
digital
Computer · Phone · Camera security
សូមអញ្ជើញមកកាន់ Digital Show Room :
ផ្ទះលេខ ៨ AEo ផ្លូវ ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : 023 555 6 777

# មាតិកា

លេខទី១៩៣ ខែធ្នូ ឆ្នាំ២០១៥
193 December 2015




## ព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ

12- Samsung សម្ពោធគេហទំព័រព័ត៌មាន .....
15- OneDrive កំណត់ថ្មីលើទំហំផ្ទុកទិន្នន័យ ..
18- Tablet របស់ NVDIA សក្តិសមសម្រាប់អ្នកលេងហ្គេម ..........................................
20- ទីផ្សាររបស់ Surface Pro 4 កំពុងតែឡើង ..........................................
21- អ្នកអាចគូររូបភាពដ៏ស្រស់ស្អាតជាមួយប៊ិក S Pen ..........................................

## Accessories Computer

22- Harman Kardon SoundSticks......
23- USB Scanner............................
24- HDD/SSD docking station ............
25- Vertical Optical Mouse .............

## Computer Review

26- LG Gram.................................
28- HP Pavilion X2................................
30- intel NUC ..........................................
32- HP Envy Curved All in one ............

## HardWare Review

34- Dark Rock Pro 3 កង្ហារត្រជាក់សំឡេងស្ងាត់បំផុត......................................
35- EK-FB Monoblocks
កង្ហារត្រជាក់ថ្មីសឡាងពី EK Water Blocks..

## ហ្គេមពេញនិយម

42- Call Of Duty Black Ops III
44- Minecraft Story Mode ...................

## New Software

46- កម្មវិធីថ្មីៗ ..........................................



AFFORDABLE RELIABLE INTERNET

CITY Link

YOUR OBVIOUS CHOICE

LEADING INTERNET SERVICE PROVIDER

# 1Mbps get 2Mbps
# 2Mbps get 4Mbps




023 220 112

www.citylink.com.kh

# មាតិកា

លេខទី១៩៣ ខែធ្នូ ឆ្នាំ២០១៥
193 December 2015




## ហ្គេមថ្មីៗ

**50** - ហ្គេមកុំព្យូទ័រថ្មីៗ

## Quick Study

**53**- របៀបពិនិត្យមើលនូវ Computer Specification............................................
**54**- វិធីសាស្ត្រក្នុងការបិទ Pop-ups នៅក្នុង Internet Explorer និង Mozilla ............
**56**- របៀបនៃការបង្កើត ឬចែកទីតាំងសម្រាប់ផ្ទុកទិន្នន័យ ..........................................

## Security

**59**- មេរោគកុំព្យូទ័រ៨ប្រភេទដែលត្រូវប្រុងប្រយ័ត្នបំផុត! ..................................................

## សំណួរមិត្តអ្នកអាន

**72** - សំណួរ និងចម្លើយ

## Top Ten Computer

**88** - ជម្រើសកុំព្យូទ័រយួរដៃទាំង១០ ................

## តារាងតម្លៃ

**94**- តារាងតម្លៃកុំព្យូទ័រ និងគ្រឿងបន្លាស់

## ផលិតផលថ្មីៗ

**79**- អារម្មណ៍ស្រស់ថ្លាជាមួយនឹង Libratone Zipp .....................................
**80**- Magic Keyboard..............................
**81**- Magic Mouse 2 ..............................

**ចាងហ្វាងការផ្សាយ**
អនុបណ្ឌិត : ប៉ុល ច័ន្ទវីរៈ

**នាយកគ្រប់គ្រង**
Mr. : JACKY SAM

**ប្រធានផ្នែកព័ត៌មាន និងនិពន្ធ**
លោក : ឆាន សុផា

**ផ្នែកព័ត៌មាន និងនិពន្ធ**
កញ្ញា : ប៉ោក លក្ខិណា
លោក : ម៉ម សុវណ្ណថា
កញ្ញា : សឿង ចាន់ថូ

**ផ្នែករចនាទំព័រ**
ប្រធាន លោក : ស្វាយ សេរីវុត្ថា
លោក : រស់ ចំរើន

**ផ្នែកទីផ្សារ**
លោក : មករា
លោក : សាយ ភិរុណ

**ផ្នែកលក់**
លោក : វង់ តុលា

**ផ្នែកតែបទំព័រ**
លោក : ឆាន សុផា
កញ្ញា : ប៉ោក លក្ខិណា

អាសយដ្ឋាន : ផ្ទះលេខ ៨ AEo
ផ្លូវលេខ ១៥៦ សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ

**ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម**
**010 67 67 67**
**018 9333337**



ទំព័រ 86





ទំព័រ 61

## បច្ចេកវិទ្យាចុងក្រោយក្នុងការព្រីន

# CONFIDENTIAL CODE



ផ្ញើលេខកូដទៅកាន់អតិថិជនរបស់អ្នកនៅក្នុងវិធីដ៏មានសុវត្ថិភាព
**100%** ជាមួយនឹងការច្នៃប្រឌិតថ្មីបំផុតរបស់យើង។




### ប្រសិទ្ធភាព

សាមញ្ញ ងាយស្រួលអនុវត្តន៍
និងងាយស្រួលប្រើប្រាស់

### ភាពអាថ៌កំបាំង

ព័ត៌មានសម្ងាត់អានបានតែម្តងប៉ុណ្ណោះ
មិនអាចត្រឡប់ម្តងទៀតបានទេ

### សុវត្ថិភាព

ព័ត៌មានធានាសុវត្ថិភាពទាំងស្រុង
ក្នុងអំឡុងពេល និងបន្ទាប់ពីការបោះពុម្ព



ធនាគារអឺរ៉ុប និងក្រុមហ៊ុនធានារ៉ាប់រងជាច្រើនកំពុងប្រើបច្ចេកវិទ្យារបស់យើង:

AIR FRANCE · BanqueAccord · CAISSE D'EPARGNE · castorama · cetelem · FINAREF · LA POSTE · GE · MACSF groupe · oney · PEUGEOT · SOCIETE GENERALE ...


#8AE0, Sangkat Veal Vong, Khan 7 Makara,
Phnom Penh City, Cambodia
Tel: (855) 16 555 889 / 018 333337

# ក្រុមហ៊ុនសាមសុងសម្ពោធគេហទំព័រព័ត៌មាន ដែលផ្តល់ជូននូវព័ត៌មាន និងឯកសារជាច្រើន




ក្រុមហ៊ុនសាមសុងអេឡិចត្រូនិចបានសម្ពោធជានូវគេហទំព័រព័ត៌មានដែលមានឈ្មោះថា « Samsung Newsroom » ដើម្បីផ្តល់ជូននូវព័ត៌មានអំពីសាមសុង និងឯកសារជាច្រើនដែលមានអាសយដ្ឋាន៖ news.samsung.com។ វាជាប្រភពទិន្នន័យផ្លូវការរបស់សាមសុងដែលផ្តោតសំខាន់ទៅលើផលិតផលថ្មីៗសេវាកម្មនិងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនទាក់ទងនឹងកិច្ចការសង្គមព័ត៌មានអំពីពាណិជ្ជកម្មព្រមទាំងបុគ្គលសំខាន់ៗនៅជុំវិញពិភពលោក។

លោក អ៊ីង យ៉ុង រី ដែលជាប្រធានទំនាក់ទំនងរបស់ក្រុមហ៊ុនសាមសុងអេឡិចត្រូនិចបានមានប្រសាសន៍ឲ្យដឹងថា៖«ខណៈពេលដែលក្រុមហ៊ុនសាមសុងកំពុងតែទទួលការពេញនិយមនៅជុំវិញពិភពលោកព្រមទាំងធ្វើការកំណត់អនាគតតាមរយៈគំនិតច្នៃប្រឌិតក៏ដូចជាបច្ចេកវិទ្យាទំនើបយើងក៏បានធ្វើការអភិវឌ្ឍជាបន្តបន្ទាប់នូវមធ្យោបាយទំនាក់ទំនងផ្សេងៗ។ គេហទំព័រថ្មីរបស់សាមសុង « Samsung Newsroom » យើងផ្តល់ឲ្យមនុស្សនៅជុំវិញពិភពលោកនូវព័ត៌មានកាន់តែលម្អិតជាង មុនអំពីក្រុមហ៊ុនសាមសុង ព្រមទាំងវិធីដែលយើងកំពុងកំណត់អនាគត ។»

គេហទំព័រថ្មីនេះត្រូវបានរៀបរៀងឡើងជាពីរភាសាគឺអង់គ្លេស និងកូរ៉េ ព្រមទាំងត្រូវបានដាក់ឲ្យដំណើរការជំនួស Samsung Tomorrow ដែលជាប្លុកផ្លូវការរបស់ក្រុមហ៊ុនសាមសុងអេឡិចត្រូនិច។

### ផ្តល់ឲ្យលោកអ្នកនូវព័ត៌មានអំពីសាមសុងនិងនៅជុំវិញពិភពលោក

គោលបំណងសំខាន់របស់គេហទំព័រនេះគឺមិនត្រឹមតែដើម្បីផ្តល់ព័ត៌មានដល់អតិថិជន និងអ្នកព័ត៌មាននូវព័ត៌មានឲ្យសមរម្យប៉ុណ្ណោះទេ ថែមទាំងផ្តល់ការយល់ដឹងកាន់តែច្បាស់អំពីក្រុមហ៊ុនសាមសុង។ គេហទំព័រមួយនេះនឹងផ្តល់ព័ត៌មានគួរឲ្យចាប់អារម្មណ៍ និងរឿងរ៉ាវល្អៗជាច្រើនអំពីសាមសុងដូចជាកិច្ចការច្នៃប្រឌិត និងសហគមន៍នៅជុំវិញពិភពលោក។

ជាផ្នែកមួយនៃបេសកកម្មរបស់យើង គេហទំព័រនេះនឹងផ្តោតសំខាន់លើប្រធានបទចំនួនពីរជាប្រចាំគឺទស្សនៈវិស័យ និងជីវិតនៅសាមសុង។

### ចំណេះដឹងពីបច្ចេកវិទ្យា និងពាណិជ្ជកម្មលំដាប់ពិភពលោក

នៅក្នុងផ្នែកទស្សនៈវិស័យ លោកអ្នកនឹងទទួលបាននូវព័ត៌មានដោយផ្ទាល់ពីអ្នកដឹកនាំរបស់ក្រុមហ៊ុនសាមសុង ព្រមទាំងការវិភាគ និងមតិយោបល់របស់អ្នកជំនាញក៏ដូចជាបុគ្គលិកដែលមានបទពិសោធន៍ជាច្រើននាក់។ ជាមួយនឹងការបង្ហាញអំពីចក្ខុវិស័យ យុទ្ធសាស្ត្រ ការរចនា និងទស្សនៈវិស័យរបស់ក្រុមហ៊ុនសាមសុង វានឹងជួយឲ្យលោកអ្នកយល់កាន់តែច្បាស់ពីពិភពលោកតាមរយៈការពិនិត្យមើលនូវនិន្នាការថ្មីៗ និងការអភិវឌ្ឍផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងសង្គមជាដើម។

### ការចែករំលែកនិង ការចូលរួមចំណែកសហគមន៍

ក្នុងផ្នែកជីវិតនៅសាមសុងនឹងនិយាយអំពីធនធានមួយដ៏សំខាន់របស់សាមសុងនោះគឺបុគ្គលិកទាំង ៣១៩.០០០នាក់ នៅជុំវិញពិភពលោក។ វាមិនត្រឹមតែផ្តល់នូវព័ត៌មានសំខាន់អំពីវប្បធម៌ និងកិច្ចការរបស់ ក្រុមហ៊ុននៅជុំវិញពិភពលោកនោះទេ វាថែមទាំងជាទីកន្លែងមួយដែលលោកអ្នកអាចស្វែងរករឿងរ៉ាវជាទីចាប់អារម្មណ៍ជាច្រើនដែលនិយាយអំពីការជម្នះឧបសគ្គ ក្តីសង្ឃឹម និងសុបិន្តរបស់បុគ្គលមួយចំនួនដែលរួមចំណែកធ្វើឲ្យក្រុមហ៊ុនសាមសុងរីកចំរើនរហូតដល់សព្វថ្ងៃ។

### ប្រភពឯកសារសំខាន់ៗសម្រាប់អតិថិជន អ្នកសារព័ត៌មាន និងពាណិជ្ជករ

គេហទំព័រនេះនៅតែផ្តល់នូវព័ត៌មានចាំបាច់មួយចំនួនអំពីក្រុមហ៊ុនដូចជា៖ ព័ត៌មានពាណិជ្ជកម្ម ព័ត៌មានអំពីជីវប្រវត្តិ និងទិន្នន័យទូទៅនិយាយពីស្ថានភាពពាណិជ្ជកម្ម និងនិរន្តរភាព។ បន្ថែមពីនេះទៀត ផ្នែកនេះក៏រួមបញ្ចូលនូវបញ្ហានិងការពិត ព្រមទាំងសំនួរចម្លើយជាច្រើនដែលអនុញ្ញាតឲ្យលោកអ្នកទទួលបាននូវព័ត៌មានដ៏ត្រឹមត្រូវមួយអំពីប្រធានបទសំខាន់ៗ និងរឿងរ៉ាវជំនួញនានា។

បន្ថែមពីនេះទៀត យើងក៏បានបន្ថែមនូវផ្នែកមួយសម្រាប់អ្នកសារព័ត៌មានដែលអាចឲ្យមានភាពងាយស្រួលក្នុងការស្រាវជ្រាវនិងស្វែងរកព័ត៌មានផ្សេងៗ៕


EMAXX 4G
Internet - WIMAX - Fiber Optics - Telecom Services
4G SPEED
AT YOUR
FINGERTIPS
No. 99, Preah Norodom,
Level 1, Phnom Penh
info@emaxxtelecom.com
www.emaxxtelecom.com
023 999 818
YOUR INTERNET
SERVICE PROVIDER


MEKONGNET
CONNECTING YOU ALL
100+ Gbps
SPEED UP TO
Speed Up
YOUR BUSINESS
MOVE TO US
023 22 66 22
www.mekongnet.com.kh sales@corp.mekongnet.com.kh




# OneDrive កំណត់ថ្មីលើទំហំផ្ទុកទិន្នន័យ

ក្រៅពីផ្ទុកទិន្នន័យក្នុងកុំព្យូទ័រ ពេលនេះបច្ចេកវិទ្យាក៏អាចឱ្យអ្នកផ្ទុកទិន្នន័យលើ Cloud ប៉ុន្តែវាត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់។ ក្រុមហ៊ុន Microsoft បានផ្លាស់ប្តូរការផ្តល់ជូនទំហំផ្ទុកទិន្នន័យទាំងការផ្តល់ជូនឥតគិតថ្លៃ និងកញ្ចប់សេវាបង់ប្រាក់។

យោងតាមការបង្ហាញក្នុង OneDrive blog បានបញ្ជាក់ថា OneDrive ត្រូវបានរចនាឡើងប្រើសម្រាប់ការផ្ទុកទិន្នន័យលើ Cloud ដែលបង្ករភាពងាយស្រួល និងមានសុវត្ថិភាព។ វាបានធ្វើឱ្យរបៀបផ្ទុកទិន្នន័យកាន់តែប្រសើរ ជាពិសេសជាសេវាកម្មដែលមានទំនាក់ទំនងជាមួយបច្ចេកវិទ្យាទូរគមនាគមន៍បណ្តាញ។

ដំបូងក្រុមហ៊ុន Microsoft បានបញ្ឈប់ការផ្តល់ជូនទំហំផ្ទុកទិន្នន័យ 1TB លើ Office 365។ ពេលនេះកុំព្យូទ័របានផ្លាស់ប្តូរសេវាកម្មថ្មីទៀតដោយផ្តល់ជូនទំហំផ្ទុកទិន្នន័យដោយឥតគិតថ្លៃកាន់តែតូចជាងមុនដោយបន្ថយទំហំពី15GB មក 5GB។ សម្រាប់អ្នកប្រើកញ្ចប់សេវាបង់ថ្លៃ100GB និង 200GB ក៏ត្រូវបានប្តូរដោយគិតចាប់ពីទំហំ 50GB ត្រូវបង់ $1.99 ក្នុងមួយខែចាប់ពីដើមឆ្នាំ 2016 ទៅ។

ក្រុមហ៊ុនបានលើកឡើងថា អតិថិជនដែលធ្លាប់ប្រើ OneDrive សូមរីករាយនឹងការផ្តល់ជូនទំហំផ្ទុកទិន្នន័យ និងការកំណត់សេវាកម្មថ្មីរបស់ក្រុមហ៊ុន។ នៅថ្ងៃមុខក្រុមហ៊ុននឹងព្យាយាមកែប្រែវាឱ្យកាន់តែប្រសើរទាំងសេវាកម្មផ្តល់ដោយឥតគិតថ្លៃ និងសេវាកម្មផ្តល់ជាកញ្ចប់៕





# CELEBRATING PCHUM BEN DAY



**HP LaserJet Pro 400 Printer M401d (CF274A)** — **$210**

- Print speed black (normal, A4) Up to **33 ppm**
- Print technology **Laser**
- Duty cycle (monthly, A4) Up to **50,000 pages**
- Print quality black (best) Up to **1200 x 1200 dpi**
- First page out black (A4, ready) **As fast as 8 sec**



**HP LaserJet Pro 400 Printer M401dn (CF278A)** — **$245**

- Print speed black (normal, A4) Up to **33 ppm**
- Print technology **Laser**
- Duty cycle (monthly, A4) Up to **50,000 pages**
- Print quality black (best) Up to **1200 x 1200 dpi**
- First page out black (A4, ready) **As fast as 8 sec**
- With **Color Screen Display**

ANANA
TRUSTED SERVICE & QUALITY

# FREE

VERBATIM
**8GB Flash Drive** = $17




&




CD OEM 2015
**1User/1Year**
= $7

## Contact Details

Building #95, Norodom Blvd,
Phnom Penh, Cambodia

Email : sales@ananacomputer.com
Website : ananacomputer.com

023 211 543
015 831 516
012 831 516
016 831 516




SPEED
1.5 MB
UPLOAD 3MB
25$

GET ONE MONTH FREE

Wicam
The best connection

#113, St. 271, Sangkat Boeung Salang, Khan Toul Kok, Phnom Penh.
Telephone: (855) 23 22 40 40 / (855) 23 22 25 35
Fax: (855) 023 22 25 26
E-mail:info@wicam.com.kh / sales@wicam.com.kh
facebook.com/wicamcorporate
twitter.com/wicamisp

# Tablet របស់ NVIDIA សក្តិសមសម្រាប់អ្នកលេងហ្គេម

NVIDIA ល្បីខ្លាំងណាស់ខាងផលិតកុំព្យូទ័រហ្គេមដែលមានក្រាហ្វិកច្បាស់ ហើយទទួលបានការគាំទ្រខ្ពស់ ហើយថ្មីៗនេះ NVIDIA បានប្រកាសបង្ហាញ Tablet ជំនាន់ថ្មីរបស់ខ្លួន ប៉ុន្តែមិនភ្ជាប់មកជាមួយខ្សែ ឬឆ្នាំងសាក និងមានតម្លៃប្រហែល 199 ដុល្លារ។

Shield Tablet K1 ជាTablet ជំនាន់ថ្មីមានលក្ខណៈសម្បត្តិមិនខុសពី Tablet ជំនាន់មុនទេ វាភ្ជាប់មេម៉ូរីក្នុងម៉ាស៊ីនទំហំ 16GB ភ្ជាប់ Ram ទំហំ 2GB ប្រើប្រព័ន្ធដំណើរការ Android 5.1.1។ K1 បំពាក់អេក្រង់ទំហំ 8 អ៊ីង ប្រើកម្រិតបង្ហាញរូបភាព 1920 x 1200 ភិចសែល។ Tablet K1 ក៏មានភ្ជាប់មកជាមួយកាមេរ៉ាទំហំ 5 មេហ្គាភិចសែល សម្រាប់ថតរូបភាព និងវីដេអូរខ្លីៗ៕






# Asus Chromebit មុខងារពិតជាអស្ចារ្យ នាំមកជាមួយ Chrome OS

Asus Chromebit ត្រូវបានក្រុមហ៊ុនប្រកាសបង្ហាញជាផ្លូវការ ហើយពេលនេះក្រុមហ៊ុន Google និង Asus ដាក់លក់វាក្នុងតម្លៃ $85។

Asus Chromebit ត្រូវបានគេហៅថា computer stick ដែលមានភ្ជាប់ Ram ទំហំ 2GB និងមេម៉ូរីទំហំ 16GB។ ជាប់នៅម្ខាងនៃ Chromebit មានផត USB និងខាងក្នុងប្រើបន្ទះ Chip ប្រភេទ Rockchip។ Asus Chromebit ត្រូវបានដាក់លក់ក្នុងសហរដ្ឋអាមេរិច និងវិបសាយ Amazon ក្នុងតម្លៃ $85។ ជាបន្តមកទៀត ក្រុមហ៊ុននឹងដាក់លក់នៅតាមបណ្តាប្រទេសផ្សេងទៀតៗដូចជា ចក្រភពអង់គ្លេស ណ័រវេស អេស្ប៉ាញ ស្វីស ហ្វាំងឡង់ជប៉ុន អូស្ត្រាលី កាណាដា ដាណឺម៉ាក តៃវ៉ាន់ និងញូវសាឡែន។

លក្ខណៈសម្បត្តិគួរឱ្យកត់សម្គាល់ computer stick នេះអាចប្រើបានជាមួយទូរទស្សន៍តាមរយៈរន្ធ HDMI ហើយវាមាន Chrome OS របស់ Google ជាស្រេច។ លើ Chrome OS អ្នកអាចបើកសារ ផ្ញើសារ ប្រើ Google Doc ប្រើ Microsoft online ប្រើGoogle Play បើកកម្មវិធី Photoshop ប្រើ Cloud លើទូរទស្សន៍ និងសកម្មភាពកម្សាន្ត Online មួយចំនួនទៀតតាមរយៈប្រព័ន្ធOS។



# ទីផ្សាររបស់ surface Pro 4 កំពុងតែឡើង មាន iPad Pro ប្រជែង

វត្តមាន surface Pro 4 របស់ក្រុមហ៊ុន Microsoft លើទីផ្សារគិតមកដល់ពេលនេះមិនទាន់បានមួយខែផង ប៉ុន្តែការប្រកួតប្រជែងលើទីផ្សារកាន់តែខ្លាំងជាពិសេសជាមួយ iPad Pro និងឧបករណ៍ផ្សេងទៀតរបស់ក្រុមហ៊ុន Apple។

Surface Pro 4 ជាឧបករណ៍ទំនើបដែលត្រូវបានរចនាឡើងដោយយកចិត្តទុកដាក់ជាពិសេសត្រូវបានត្រួតពិនិត្យពីម៉ូដែលច្បងពីរគ្រឿង Surface Pro 2 និង Surface Pro 3។ វាជា Tablet ទំនើបដែលអាចប្រើប្រាស់ជំនួសកុំព្យូទ័របាន។ ទន្ទឹមនឹងការដាក់លក់ Surface Pro 4 លើទីផ្សារ វាមានលក្ខណៈពិសេសគួរឱ្យចាប់អារម្មណ៍ដូចជា៖

- មានតួនាទីជាកុំព្យូទ័រ និងជា Tablet ផងដើម្បីបំពេញតម្រូវការគ្រប់ប្រភេទរបស់អ្នកប្រើប្រាស់
- មាន Surface Pen ភ្ជាប់មកជាមួយមិនចាំបាច់ប៉ះបញ្ចាផ្ទាល់
- Type Cover ថ្មីមានកម្រាស់ក្រាស់បន្តិច សម្រាប់ភ្ជាប់ Keyboard ឱ្យកាន់តែកៀកជិតគ្នាងាយស្រួលប្រើ
- កម្រិតការពារអេក្រង់ 1,024 កាត់បន្ថយពន្លឺពណ៌ខៀវ
- ទំហំអេក្រង់តូចល្មម 12.3 អ៊ីងងាយស្រួលកាន់នៅពេលប្រើជា Tablet និងលេងហ្គេមកម្សាន្តផ្សេងៗ
- មានច្រើនទំហំសម្រាប់ជ្រើសរើស

128 GB 6th Generation Intel® Core™ M3 with 4 GB of RAM
256 GB 6th Generation Intel® Core™ i5 with 8 GB of RAM
256 GB 6th Generation Intel® Core™ i7 with 8 GB of RAM
256 GB 6th Generation Intel® Core™ i7 with 16 GB of RAM
512 GB 6th Generation Intel® Core™ i7 with 16 GB of RAM

ក្នុងខណៈពេលដែលទីផ្សារលក់ចេញរបស់ Surface Pro 4 កំពុងតែមមាញឹកក្រុមហ៊ុន Apple បានប្រកាស iPad Pro បំពាក់អេក្រង់ទំហំ 12.9 ប្រភេទ 12.9 និងប្រើ Chip ប្រភេទ 64-bit A9X។ ជាងនេះវាភ្ជាប់មកជាមួយប៊ិក Apple Pencil និងស្មាត Keyboard ។ iPad នេះប្រើ CPU ខ្លាំងជាង iPad Air 2 ពីរដង និងប្រើការប៉ះបញ្ជាលើអេក្រង់ជា Multi-Touch។ សម្រាប់ទំហំរបស់វាមិនធំពេក វាសក្តិសមបំផុតសម្រាប់អ្នកប្រើប្រាស់បច្ចុប្បន្ន។iPad Pro មានកម្រាស់ស្តើង ភ្លឺ និងភ្ជាប់មេម៉ូរីបីប្រភេទ 32GB ឬ 128GB រួមជាមួយជម្រើសបីពណ៌ប្រាក់ មាស និងពណ៌ប្រផេះ។

ពេលនេះ វត្តមានរបស់ iPad Pro កំពុងតែប្រកួតប្រជែងទីផ្សាររបស់ Surface Pro 4 យ៉ាងខ្លាំង តែទោះជាយ៉ាងណា Surface Pro 4 នៅតែបន្តជំរុញទីផ្សារលក់ឱ្យកាន់តែខ្លាំងដើម្បីទទួលបានទីផ្សារលក់ចេញខ្ពស់។



# អ្នកអាចគូររូបភាពដ៏ស្រស់ស្អាតជាមួយប៊ិក S Pen

ជាធម្មតាលោកអ្នកចូលចិត្តចែករំលែកគំនិតថ្មីៗនិងអារម្មណ៍ផ្ទាល់ខ្លួនទៅមនុស្សដែលលោកអ្នកស្គាល់។ សម្រាប់អ្នកដែលប្រើប្រាស់ Galaxy Note5 និង Galaxy Tab S2 លោកអ្នកអាចប្រើដើម្បីគូររូបបញ្ជាក់ពីអារម្មណ៍របស់លោកអ្នកព្រមទាំងចែករំលែក ជាមួយមិត្ត ភ័ក្តិតាមរយៈ PEN.UP។

PEN.UP គឺជាកម្មវិធីមួយដែលអាចឲ្យលោកអ្នកបង្ហោះ និងចែករំលែករូបគំនូររបស់លោកអ្នកព្រមទាំងមានកម្មវិធីធ្វើឱ្យរូបគំនូរកាន់តែស្អាតថែមទៀតដោយប្រើប៊ិក S Pen នេះ។ លោកអ្នកគ្រាន់តែចុះឈ្មោះប្រើកម្មវិធីនេះជាមួយនឹងគណនីបណ្ដាញសង្គមដែលលោកអ្នកកំពុងប្រើដូចជា Facebook និង Tweeter ជាដើម។ តោះយើងនាំគ្នាទៅមើលទាំងអស់គ្នាថា PEN.UP គេប្រើដូចម្ដេចទៅ។

PEN.UP មិនត្រឹមតែអាចឱ្យលោកអ្នកចែករំលែករូបគំនូររបស់លោកអ្នកនោះទេ លោកអ្នកក៏អាចប្រើវាជាមួយ apps ផ្សេងដ៏ទៃទៀតដើម្បីគូរគំនូរបានកាន់តែស្អាត។ វិចិត្រករជនកូរ៉េម្នាក់ឈ្មោះម៉ុនភិកបានប្រើ PEN.UP និង Infinite Painter ដើម្បីគូររូបក្មេងស្រីម្នាក់ដោយប្រើចេប្ពិត។ រូបគំនូរនេះពិតជាមានលក្ខណៈដូចរូបពិតណាស់។ មុនដំបូងគាត់គ្រាន់តែចាប់ផ្ដើមគូសខ្មៀសចុះឡើងបន្តិចប៉ុណ្ណោះ បន្ទាប់មកទើបលេចចេញនូវរូបភាពដ៏ស្រស់ស្អាតមួយ។ លោក ម៉ុនភិក ក៏បានបង្ហាញនូវវិធីសាស្ត្រគូរគំនូរទេសភាពផងដែរ។

ចំណែកឯវិចិត្រករ ជុនសឹង ជាក និង ដេសឹង សូ បានរួមគ្នាគូរគំនូរជីវចលដែលមានលក្ខណៈប្លែកៗនិងមានភាពរស់រវើកទាក់ទាញអ្នកទស្សនា។ គាត់បានគូររូបខ្លាឃ្មុំនៅតំបន់ប៉ូលដែលមានពណ៌សដូចព្រិល រួចហើយពួកគាត់បានបង្ហោះរូបចូល ទៅក្នុង PEN.UP បន្ទាប់ពីគូរចប់ដើម្បីចែករំលែកជាមួយអ្នកផ្សេងដ៏ទៃទៀត។

តាមរយៈវីដេអូមួយនេះ កញ្ញា ប៊ិន បង្ហាញពីការគូររូបបន្ថែមទៅលើរូបថតដែលជាការដាក់បញ្ចូលគ្នានូវរូបភាពពិត និងរូបគំនូរដោយប្រើកម្មវិធី ArtFlow app។ គាត់បានគូរ បន្ថែមរូបមនុស្សយន្តទៅលើរូបទេសភាពមួយដ៏ស្អាតដោយប្រើវិធីងាយៗ។ បន្ទាប់មក គាត់ក៏បានបង្ហាញពីរបៀបបង្ហោះរូបគំនូរនេះចូលទៅក្នុង PEN.UP ផងដែរ។

ទាំងនេះគឺជាវិធីងាយក្នុងការប្រើប៊ិក S Pen គូររូបជាមួយកម្មវិធី PEN.UP ដើម្បីចែករំលែកនូវអារម្មណ៍ និងភាពច្នៃប្រឌិតរបស់លោកអ្នក។ មិនថាលោកអ្នកប្រើ Galaxy Note5 ឬក៏ Galaxy Tab S2 លោកអ្នកសុទ្ធតែអាចបង្ហាញសមត្ថភាពសិល្បៈបានដូចគ្នា។ សាមសុងជួយឲ្យលោកអ្នកចែករំលែកពីបទពិសោធន៍និងអារម្មណ៍កាន់តែងាយស្រួលជាងមុន៕



# ឧបករណ៍អេឡិចត្រូនិចជំនួយ Accessories



## កាន់តែទាន់សម័យជាមួយនឹង Harman Kardon SoundSticks

ឧបករណ៍ Harman Kardon SoundSticks គឺជាឧបករណ៍បំពងសំឡេងដែលដើរដោយប្រព័ន្ធ Wireless ហើយអ្នកអាចភ្ជាប់ពីកុំព្យូទ័រ laptop ទូរស័ព្ទ iPhone ឧបករណ៍ iPad ឧបករណ៍ tablet ឬឧបករណ៍ MP3 player របស់អ្នកទៅកាន់ឧបករណ៍នេះបានតាមរយៈប្រព័ន្ធ Bluetooth បានយ៉ាងងាយស្រួលបំផុត។ បើពិនិត្យតាមភាពជាក់ស្តែង ឧបករណ៍នេះមានដាក់ភ្ជាប់ក្បាល speakers ចំនួន 8 គ្រាប់ដូចនេះអ្នកអាចទទួលបានសំឡេងខ្លាំង ហើយយ៉ាងច្បាស់ល្អ ជាពិសេសនោះគឺ វាបានដាក់ប្រព័ន្ធបញ្ជាដោយការប៉ះបញ្ជាដ៏ទំនើបក្នុងការគ្រប់គ្រងទៅលើកម្រិតនៃសំឡេង និងការ mute ជាដើមនោះ៕





## ជួយអ្នកដើម្បីធ្វើបទបង្ហាញ Online

នេះគឺជាឧបករណ៍ USB scanner និងជា presentation tool យួរដៃមួយ ដែលជួយថែរក្សាឯសាររបស់អ្នក ហើយអាចឱ្យអ្នកយកពួកវាទៅកាន់គ្រប់ទីកន្លែងដើម្បីជាជំនួយការដល់អ្នកក្នុងការធ្វើបទបង្ហាញបានមិនថាកាលៈទេសៈបែបណានោះទេ។ ជាមួយនឹងឧបករណ៍នេះ អ្នកអាចប្រើប្រាស់មុខងារពិសេសៗរបស់វាជាច្រើនជាក់ស្តែងដូចជាវាអាច scan រូបភាព business cards ឬសូម្បីតែសៀវភៅ បានយ៉ាងច្បាស់ ពោលគឺវាផ្តល់រូបភាពដែលមាន resolution ខ្ពស់បានរហូតដល់ទៅ 2592 x 1944 pixels ឯណោះ។ សម្រាប់មុខងារមួយទៀតរបស់វានោះគឺវាអនុញ្ញាតិឲ្យអ្នកអាចធ្វើបទបង្ហាញដោយធ្វើការតភ្ជាប់ទៅកាន់កម្មវិធីមួយចំនួនរួមមាន Skype កម្មវិធី MSN កម្មវិធី Google Talk កម្មវិធី AIM កម្មវិធី ICQ និងកម្មវិធី QQ ជាដើម៕



## ចូលទៅកាន់ពិភពនៃសង្គ្រាម ជាមួយនឹងឧបករណ៍ដ៏មានគុណភាពបំផុត

នេះគឺជាឧបករណ៍ដែលអាចនាំយកអ្នកទៅកាន់ពិភពនៃហ្គេមទាំងឡាយ ជាមួយនឹងប្រព័ន្ធទំនាក់ទំនង ដ៏ល្អឥតខ្ចោះមួយ ហើយមានភាពងាយស្រួលក្នុងការប្រើប្រាស់បំផុត ពីព្រោះវាស្រាល និងងាយស្រួលក្នុងការពាក់។ វាជាកាសមួយប្រភេទដែលប្រើប្រាស់ប្រព័ន្ធ Bluetooth 2.0 ហើយអាចឱ្យអ្នកធ្វើការតភ្ជាប់មិនថាកុំព្យូទ័រ laptop ឬឧបករណ៍ផ្សេងទៀតនោះទេ ជាក់ស្តែងនោះអ្នកអាចប្រើវាជាមួយនឹងស្មាតហ្វូនរបស់អ្នក សម្រាប់ chat ជាសំឡេង ឬវីដេអូក៏បាន។ បើនិយាយអំពីគុណភាពសំឡេងរបស់វាវិញ វាផ្តល់សម្លេងបានច្បាស់ល្អ ហើយបានដាក់បំពាក់ដោយប្រព័ន្ធកាត់បន្ថយសំឡេងរំខានថែមទៀតផង។ ចំពោះនៅផ្នែកខាងក្នុងនៃឧបករណ៍នេះវិញមានថ្មដែលមានកម្រិតថាមពល 80mAh ដែលជួយឱ្យអ្នកបន្តប្រើប្រាស់បានកាន់តែយូរ។ ចាំដល់ណាទៀត ចាប់ផ្តើម log in បង្កើតក្រុមដើម្បីលេងហ្គេមប្រភេទ FPS ដែលមាន ដូចជា Crysis 3 ហ្គេម Call of Duty Black Ops និងហ្គេម Far Cry 3 ទាំងអស់គ្នា៕




# កាន់តែលឿន និងឆ្លាតវៃជាងអ្វីដែលធ្លាប់មានពីមុន

ឧបករណ៍ HDD/SSD docking station គឺជាឧបករណ៍សម្រាប់ copy drives មួយប្រភេទដែលមានល្បឿនលឿនដូចទៅនឹង USB 3.0 អញ្ចឹងដែរ។ ជាមួយនឹងមុខងាររបស់វាអ្នកអាចធ្វើការ copy hard disk របស់កុំព្យូទ័ររបស់អ្នកជាមួយនឹងកុំព្យូទ័រ Mac បានយ៉ាងងាយស្រួលទោះបីជាពួកវាមានប្រភេទ hard disks ផ្សេងគ្នាក៏ដោយ។ ដូចគ្នានេះដែរឧបករណ៍នេះបាននាំមកជាមួយនឹងមុខងារប៉ះបញ្ជាដើម្បីធ្វើការ copy ដោយមិនទាមទារឲ្យអ្នកចាំបាច់ប្រើប្រាស់កុំព្យូទ័រនោះទេ ពោលគឺអ្នកគ្រាន់តែអ្នកដាក់ hard disk ទីមួយចូលទៅក្នុងរន្ធ source (ទីតាំងដែលត្រូវថតចម្លងចេញ) ហើយដាក់ hard disk ទីពីរទៅកាន់ទីតាំង target (ទីតាំងទទួលនូវរាល់ការថតចម្លងទាំងឡាយ) បន្ទាប់មកចុចលើប៊ូតុង backup រង់ចាំតែបន្តិចនោះអ្នកនឹងអាច copy បានយ៉ាងជោគជ័យ៕




# ប្រមូលផ្តុំមុខងារទាំង 5 នៅក្នុងឧបករណ៍តែមួយ

នេះគឺជាឧបករណ៍ Vertical Optical Mouse ដែលវាជា mouse ដែលមានមុខងារ 5 ផ្សេងគ្នាសម្រាប់ជាបទពិសោធន៍ថ្មីនៃអ្នកប្រើប្រាស់គ្រប់គ្នា។ គ្រប់ពេលទាំងអស់ដែលអ្នកចាប់កាន់វា អ្នកនឹងទទួលបានអារម្មណ៍ថាអ្នកប្រើប្រាស់វាបានត្រឹមត្រូវតាមមុខងារដែលអ្នកចង់បានពីព្រោះថាវាត្រូវបានរចនាឡើងឱ្យត្រូវទៅនឹងទំហំដៃរបស់អ្នកប្រើប្រាស់ហើយគ្រប់គ្រងមុខងារទាំងអស់បាន រួមមានមុខងារដូចជា left click មុខងារ right click មុខងារ scroll កង់វិល មុខងារ page up និងមុខងារ page up។ បច្ចេកវិទ្យាថ្មីមួយនេះ ជួយឲ្យអ្នកធ្វើការ upgrade mouse របស់អ្នកឲ្យកាន់តែមានភាពងាយស្រួលជាងមុខ ហើយវាក៏អាចជាកាដូដ៏ល្អបំផុតសម្រាប់មិត្តភក្តិរបស់អ្នកផងដែរ៕






# LG gram 14
## រូបរាងសាមញ្ញ ប៉ុន្តែរឹងមាំ

LG gram 14 ជាកុំព្យូទ័រយួរដៃថ្មីដែលរចនាឡើងសម្រាប់បំពេញតម្រូវការអ្នកប្រើប្រាស់ក្នុងការងារ និងប្រើកម្មវិធីកម្សាន្តផ្សេងៗ។ វាជាកុំព្យូទ័រធន់កណ្តាលដែលបំពាក់អេក្រង់ទំហំ 14 អ៊ីងទូលាយងាយស្រួលដល់ការបើក View។

### ការរចនា

កុំព្យូទ័រ LG gram 14 ត្រូវបានរចនាឡើងមានរូបរាងសាមញ្ញ ប៉ុន្តែរឹងមាំ និងធន់។ កុំព្យូទ័រនេះមានលក្ខណៈរឹងមាំ ដោយលោហៈធាតុដែលផលិតវាយកមកពីលោហៈធាតុរបស់ឡានប្រណាំង ហើយកម្រាស់ពាក់កណ្តាលរបស់វាត្រូវបានគេស្រោបដោយសារធាតុកាបូនម៉ាញ៉េស្យូម និងលីចូមម៉ាញ៉េស្យូមដែលជួយការពារ រួមទាំងបន្ថែមសោភ័ណភាពកុំព្យូទ័រនេះ





កាន់តែស្រស់ស្អាតភ្លឺរលើបរលោង និងរឹងមាំ។ នៅផ្នែកខាងមុខលើអេក្រង់ Full HD មានកម្រិតពន្លឺភ្លឺច្បាស់ត្រជាក់ភ្នែក 1920x1080 ងាយស្រួលបើកកម្មវិធី និងចាក់វីដេអូកម្សាន្តផ្សេងៗ។ នៅកណ្តាលនៃអេក្រង់ខាងមុខមាន webcamដែលជាកាមេរ៉ាអាចថតវីដេអូនៅអង្គប្រជុំក្នុងកម្រិតពន្លឺសមស្រប 1.3MHDកាន់បន្ថយពន្លឺខៀវមានកម្រិតទាបបំផុតដែលមិនបណ្តាលឱ្យប៉ះពាល់ដល់ភ្នែករបស់អ្នក។

**ការតភ្ជាប់**

កុំព្យូទ័រនេះត្រូវបានបញ្ចូលក្រាហ្វិកកាតប្រភេទ Intel HD Graphic 5500 ដែលធ្វើឱ្យរូបភាពកាន់តែច្បាស់ និងកម្មវិធីកាត់តរូបភាពកាន់តែងាយស្រួលប្រើ ជាពិសសអ្នកក៏អាចលេងហ្គេមកុំព្យូទ័រ ឬមើលរឿងកាន់តែសប្បាយរីករាយ។ វាមានដំណើរការយ៉ាងរលូនដោយបន្ទះ Chip ប្រភេទ Core i7 ល្បឿន 2.4GHz។ LG gram អាចផ្ទុកទិន្នន័យបានរាប់រយ File ដោយប្រើ SSD ទំហំ 128GB ឬ 256GB និងមេម៉ូរីរបស់ DDR3 ទំហំ 8GB។

**Keyboard**

Keyboard របស់កុំព្យូទ័រ LG gram 14 ត្រូវបានបំពាក់តម្រៀបគ្នាដោយគ្រាប់ Key ដ៏ច្រើន ដែលប្រើប្រាស់សម្រាប់ការជំនួយការវាយអត្ថបទប្រើ Short Cut បើក និងដំណើរការកម្មវិធីផ្សេងៗ។ គ្រាប់ចុចរចនាមកមានលក្ខណៈទន់ល្មើយ ងាយស្រួលវាយ មិនគាំង ហើយកាន់តែពិសេសវាអមដោយ Pad តូចមួយសម្រាប់គ្រប់គ្រងលើកម្មវិធី និងបញ្ជាបានយ៉ាងរហ័ស និងមានលក្ខណៈរស់រវើក៕




## លក្ខណៈទូទៅ

| | |
|---|---|
| PROCESSOR CPU Brand | Intel |
| CPU Core | i7 |
| CPU Type | 5500U |
| CPU Speed | 2.4 GHz |
| MEMORY Total Memory | 8GB DDR3L 1600MHz |
| Cache | L3 Cache 3MB |
| HARD DRIVE | SSD 256GB |
| DISPLAY Screen Size | 14.0" IPS LCD (1920 x 1080) |
| Graphics | Intel HD Graphics 5500 |
| Battery Life | 7.5 Hours |
| MATERIAL | Carbon Magnesium & Lithium Magnesium |
| DIMENSIONS/WEIGHT | |
| Dimensions (WxHxD) | 12.8" x 8.9" x 0.5" |
| Shipping Dimensions (WxHxD) | 17.01" x 10.71" x 1.61" |
| Weight | 2.16 lbs |
| Shipping Weight | 3.48 lbs |




# អស្ចារ្យសមត្ថភាពរបស់ Pavilion x2 ធ្វើឱ្យជីវិតកាន់តែរីករាយ




Pavilion x2 ជាឧបករណ៍ជំនាន់ថ្មីរបស់ក្រុមហ៊ុន HP រចនាមកមានរូបរាងគួរឱ្យទាក់ទាញជាមួយបច្ចេកវិទ្យាចំរុះដ៏សម្បូរបែប។ បើអ្នកកំពុង តែរកមើលកុំព្យូទ័រនោះ Pavilion x2 ជាជម្រើសដ៏ល្អរបស់អ្នកដែលអាចបំពេញតម្រូវការរបស់អ្នកបានបួនបែបដែលបានផ្តល់ភាពងាយស្រួលយ៉ាងខ្លាំងដល់អ្នកក្នុងការធ្វើការងារ ឬការកម្សាន្ត។ អ្នកកាន់តែមានទំនុកចិត្តខ្ពស់ក្នុងការប្រើប្រាស់កុំព្យូទ័រ Pavilion x2 ដោយអាចដោះ Keyboard ចេញបានដើម្បីដំណើរការកម្មវិធីជាច្រើន រួមមានទាំងកម្មវិធីហ្គេម ឬបត់ Keyboard ទៅម្ខាងដើម្បីទទួលបានជើងបញ្ឈរដ៏រឹងមាំដើម្បីចាក់វីដេអូ ឬតន្ត្រី និងប្រើប្រាស់ជា Tablet សម្រាប់ការអានសៀវភៅ ឬមើលប្លុកផ្សេងៗ កាន់តែងាយស្រួលរួមជាមួយសមត្ថភាពកុំព្យូទ័រដែលផ្លាស់ប្តូរប្រតិទិនរបស់អ្នកយ៉ាងទៀងទាត់ និងអាចទូទាត់ការចំណាយផ្សេងៗលើ Online ផ្សេងៗដោយមានសុវត្ថិភាព។

កាន់តែពិសេសសម្រាប់ថាមពលដែលកុំព្យូទ័រ Pavilion x2 មានអាចឱ្យអ្នកប្រើប្រាស់បាន 10 ម៉ោង និង 45 នាទីពេញក្នុងពេលសាកថ្មម្តង នោះអ្នកអាចធ្វើការងារ មើលវីដេអូ ចាក់តន្ត្រី បើកមើលវិបសាយយ៉ាងមានទំនុកចិត្តទោះបីភ្លេចយកឆ្នាំងសាកតាមខ្លួន។

ប្រើប្រាស់ Pavilion x2 មិនចាំបាច់ខ្វល់ពីការចែកចាយឯកសារជាមួយការភ្ជាប់ដ៏សម្បូរបែបដូចជាភ្ជាប់រន្ធជើងកាត SD សម្រាប់ឱ្យអ្នកចម្លងរូបថត វីដេអូពីឧបករណ៍ផ្សេងទៀត ឬទៅឧបករណ៍ផ្សេងទៀត។ ម៉្យាងទៀត ផត HDMI ប្រភេទមីក្រូសម្រាប់បញ្ជូនវីដេអូ ឬបទបង្ហាញលើម៉ូនីទ័ររបស់អ្នក ឬទូរទស្សន៍។ ផតមួយទៀតប្រភេទ Type-Cសម្រាប់សាកថ្មទទួលបានថាមពលពេញមួយថ្ងៃ រួមជាមួយផតមួយទៀត USB 2.0 សម្រាប់ឱ្យឧបករណ៍ផ្សេងៗទៀតដែលប្រើផតប្រភេទនេះភ្ជាប់បានដើម្បីផ្ទេរឯកសារ ឬសាកថ្ម។

## ប្រើបន្ទះ Intel

សម្រួលដល់ការងារគ្រប់ប្រភេទរបស់អ្នកជាមួយ Intel© និងធ្វើឱ្យការបង្ហាញកាន់តែមានលក្ខណៈរលូន។

## ជម្រើសពណ៌ពេញនិយម

អ្នកអាចរើសពណ៌ណាមួយដែលជាចំណង់ចំណូលចិត្តរបស់អ្នកដោយសារ Pavilion x2 រចនាមានបីពណ៌ ក្រហម ស និងខ្មៅ។

## កង្ហាបន្ថយកម្តៅ

ម៉ាស៊ីនកុំព្យូទ័ររបស់អ្នកកាន់តែមានដំណើរការស្រួល ស្ងាត់ ហើយមិនងាយឡើងកម្តៅ គ្មានសំឡេងរំខានជាមួយកង្ហារដែលបង្កប់ខាងក្នុងយ៉ាងមានប្រសិទ្ធភាព៕




## លក្ខណៈទូទៅ

| | |
|---|---|
| CPU type | Intel Atom Z3745 |
| CPU speed | 1330 Mhz |
| Graphics | Intel HD Graphics |
| Fanless | YES |
| OS | Windows 8.1 |
| **Display** | |
| Size | 10.1" 1280 X 800 |
| Screen Type | LED-Backlit LCD |
| Touchscreen | Multi-touch |
| RAM | 2048 MB |
| SSD | 32 GB |
| Battery | 35 Wh |
| Weight | 550gm |
| Size | 264/170/9.6 mm |
| Size | 10.4/6.7/0.4 inches |






# Intel NUC

## ការប្រើប្រាស់កាន់តែសម្បូរបែប

Intel® Unite™ ឧបករណ៍ថ្មីរចនាដោយក្រុមហ៊ុន Intel នាំមកនូវសមត្ថភាពច្រើនយ៉ាង ជាពិសេសមុខងាររបស់វាងាយស្រួលប្រើសមស្របតាមសម័យកាលបច្ចុប្បន្ន។ Intel® Unite™ ជាឧបករណ៍ប្រើសម្រាប់បំពាក់ក្នុងបន្ទប់ប្រជុំធំៗដើម្បីសម្រួលកិច្ចការប្រជុំឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។ លើសពីនេះ វាមាន software ចំនួនពីរគឺ Intel® NUC និង Intel® Unite™ ដែលធ្វើឱ្យការប្រើប្រាស់មានប្រសិទ្ធភាពបំផុតដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់។ ការប្រើប្រាស់កាន់តែសម្បូរបែប មិនត្រឹមតែប្រើបានក្នុងបន្ទប់ប្រជុំទេ ប៉ុន្តែអ្នកអាចប្រើប្រាស់ដើម្បីបំពេញតម្រូវការផ្ទាល់ខ្លួនបានជាច្រើនទៀត។

សម្រាប់ការកម្សាន្តនៅផ្ទះ៖ អ្នកក៏អាចប្រើប្រាស់វាដោយអាចភ្ជាប់ឧបករណ៍នេះត្រង់ផត HDMI* NUC6i3SYH ដើម្បីទទួលបានទស្សនីយភាពត្រជាក់ភ្នែកកម្រិត 4K ភ្លឺច្បាស់ដូចធម្មជាតិពិតៗ ដែលនាំឱ្យការកម្សាន្តរបស់អ្នកកាន់តែសប្បាយរីករាយថែមមួយកម្រិតទៀត។

### ការប្រើប្រាស់

Intel® Unite™ មានភាពទាន់សម័យបំផុតដែលអាចប្រើបានជាមួយ Windows® 10 សក្តិសមជាមួយថាមពលដំណើរការ Intel® Core™ ធ្វើឱ្យមុខងារកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។ ក្នុងដំណើការបិទ បើកកាន់តែរហ័ស និងមានភាពងាយស្រួល ជាពិសេសការប្រើប្រាស់អ៊ីនធើណែតលឿនរហ័សទាន់ចិត្ត។ កម្មវិធីរបស់វាមានសណ្តាប់ធ្នាប់ ហើយប្រើប្រាស់បានកាន់តែយូរជាមួយសមត្ថភាពកាន់ភ្លើងដ៏ល្អ។



## បច្ចេកវិទ្យាសម្បូរបែប

Intel® Unite™ ប្រើក្រាហ្វិកដែលមានលក្ខណៈល្អប្រសើរមិនចាំបាច់បន្ថែមក្រាហ្វិកខាងក្រៅ ក៏ទទួលបានគុណភាពបង្ហាញភ្លឺច្បាស់កម្រិត HD។

ដើម្បីការកម្សាន្តដោយសុវត្ថិភាព អ្នកក៏អាចបន្ថែមស្រទាប់ការពារមួយកម្រិតទៀត ដើម្បីភាពងាយស្រួលក្នុងការគ្រប់គ្រង និងកំណត់សុវត្ថិភាពនៅពេលលុកចូលរំលោភផ្សេងៗ។

ក្រៅពីនេះ វាថែមទាំងមានប្រព័ន្ធសំឡេងដ៏ល្អ Intel® High Definition Audio ផ្តល់នូវគុណភាពសម្លេងខ្ពស់ រងំ រំពងដែលញាំងឱ្យការចាក់ចម្រៀង ឬវីដេអូកាន់តែលឺច្បាស់។

ចំណុចគួរឱ្យចាប់អារម្មណ៍មួយទៀត ជាមួយទំហំផ្ទុកទិន្នន័យដ៏សម្បូរបែប និងមានល្បឿនលឿនប្រភេទ Intel® Solid-State Drives ដែលជាកត្តាឱ្យការបញ្ជូនទិន្នន័យបានកាន់តែរហ័ស។

### Intel® Wireless Products

Intel® Unite™ គ្រប់ដណ្តប់ដោយបណ្តាញ wireless ដែលមានល្បឿនលឿនជាងឧបករណ៍នានាៗចំនួន 3 ដង ដោយប្រើ Intel® wireless ហើយអ្នកអាចទាញយក ឬភ្ជាប់សេវាបានរហ័សទាន់ចិត្ត។

### Remote keyboard

លក្ខណៈងាយស្រួលមួយទៀត អ្នកថែមទាំងអាចប្រើប្រាស់កម្មវិធីស្មាតហ្វូន ឬ tablet ជា keyboard ដើម្បីគ្រប់គ្រងបញ្ជាវា ផ្តល់នូវភាពសប្បាយរីករាយប្លែកថែមមួយកម្រិតទៀត៕




### លក្ខណៈទូទៅ

| | |
|---|---|
| **Design** | |
| Weight | 2.4 lbs |
| Width | 4.53 in |
| Height | 1.92 in |
| Depth | 4.37 in |
| **Memory** | |
| RAM | DDR3L 16 GB |
| RAM Speed | 1,600 MHz |
| **Software** | |
| OS | Microsoft Windows |
| **Processor** | |
| Model | Core i7-5557U |
| Speed | 3.4 GHz 2 Cores |
| **Graphics** | |
| Model | Iris Graphics 6100 |
| **Storage** | |
| Storage type | SSD |








# HP ENVY Curved All-in-One

## ផ្តល់បទពិសោធន៍ថ្មីដល់ជីវិត

បច្ចេកវិទ្យាកាន់តែរីកចំរើន ក្រុមហ៊ុន HP បានផលិត PC រាងកោងមានអេក្រង់ធំដែលទទួលបានចំណាប់អារម្មណ៍ខ្ពស់ពីសំណាក់អ្នកធ្វើការងារ ក៏ដូចជាអ្នករចនារៀបសាយ ឬកាត់តរូបភាពអាជីព។

HP ENVY រចនាមានរាងកោងប្រើអេក្រង់បង្ហាញទំហំ 34 អ៊ីងជាមួយកម្រិតបង្ហាញភ្លឺច្បាស់ត្រជាក់ភ្នែក WQHD (3440x1440)




2 មានពន្លឺភ្លឺច្បាស់ត្រជាក់ភ្នែក។ ម៉ូនីទ័រវាងកោង ប្រើជើងទម្រពណ៌ប្រាក់សងខាង ដោយម្ខាងជើងបែកខ្នែងពីរសម្រាប់ទប់លំនឹង អមជាមួយ Keyboard និង Mouse ដែលប្រើ Bluetooth។ លើផ្ទៃអេក្រង់ធំទូលាយងាយស្រួលធ្វើការងារ ជាពិសេសគុណភាពបង្ហាញរូបភាពច្បាស់ បន្ថែមភាពងាយស្រួលដល់អ្នកចូលចិត្តរចនាម៉ូដ ឬកាត់តរូបភាពផ្សេងៗ។

## គុណភាពបង្ហាញរឹតតែពិសេស

កុំព្យូទ័រនេះប្រើប្រព័ន្ធដំណើរការជំនាន់ទី6 ប្រភេទ Intel® Core™ ធ្វើឱ្យល្បឿនកម្មវិធីកាន់តែល្អប្រសើរជាមួយអង្គចងចាំទំហំ 16GB ផ្ទុកឯកសាររបស់អ្នកបានរាប់ពាន់ File។ កាន់តែពិសេសជាមួយក្រាហ្វិក NVIDIA GeForce 960A ធ្វើឱ្យរូបភាពភ្លឺច្បាស់ស្រស់ស្អាតដូចធម្មជាតិ ជាពិសេសអ្នកអាចកម្សាន្តហ្គេមកាន់តែរីករាយ។

## ប្រព័ន្ធសំឡេង

វាមានប្រព័ន្ធសំឡេងលឺច្បាស់ ល្អ បំពងរំពិរោះរណ្ដំ អ្នកកាន់តែទទួលបានភាពសប្បាយរីករាយបន្ថែមដោយអាចចាក់តន្ត្រី វីដេអូដែលមានសំឡេងល្អ ជាងនេះសម្រាប់អ្នកកាត់តបទភ្លេង ឬវីដេអូកាន់តែមានភាពងាយស្រួលក្នុងពេលធ្វើការស្ដាប់។

## ប្រព័ន្ធដំណើរការទាន់សម័យ

Windows 10 + HP មានលក្ខណៈទូលំទូលាយអាចបន្ថែមកម្រិតប្រើប្រាស់ជាមួយបទពិសោធន៍ថ្មីក្នុងការគ្រប់គ្រង និងប្រើប្រាស់កម្មវិធី៕

### លក្ខណៈទូទៅ

- **Processor:** 6th generation Intel® Core™ i5-6400T processor(2b)
- **Integrated Display:** 34" curved diagonal widescreen IPS Quad HD+(38) LED backlit edge-to-edge
- **Memory:** 12GB DDR4-2133 SDRAM memory(3) 1x8GB
- **Hard drive:** 1TB 5400RPM
- **Graphics:** NVIDIA® GeForce® 960A graphics card with 2GB GDDR5 dedicated memory(13)



Hardware Review




# DARK ROCK PRO 3

## កង្ហារត្រជាក់ សំឡេងស្ងាត់បំផុត



DARK ROCK PRO 3 ជាកង្ហារត្រជាក់ “ដែលមានសំឡេងស្ងាត់បំផុត និងដំណើរការយ៉ាងរលូន” ដែលអ្នកមិនធ្លាប់បានជួប។ កង្ហារត្រជាក់នេះមានមុខងារកាន់តែល្អក្នុងការកាត់បន្ថយនូវសំឡេងរំខាននៅក្នុងកង្ហារធ្វើឱ្យម៉ាស៊ីនដំណើរការស្ងាត់ និងគ្មានភាពរអាក់រអួលនោះទេ។

បើទោះបីជាវាមានមុខងារជាច្រើនដែលជាភាពខុសគ្នារវាង DARK ROCK PRO 3 និងម៉ូដែលថ្មីផ្សេងទៀត កង្ហារមួយនេះគឺមានសភាពរឹងមាំ និងធន់បំផុតព្រោះរូបរាងរបស់វាមានទំហំដល់ទៅ 135mm រួមបញ្ចូលទាំងកង្ហារវិល Big Air Cooler ប្រវែង 6.6’’ បក់ខ្យល់បានខ្លាំង និងស្ងាត់ល្អ។ ចំនែកកង្ហារនៅផ្នែកខាងមុខមានទំហំដល់ទៅ 120mm ដែលអាចភ្ជាប់ជាមួយនឹង Power Connector ហើយកង្ហារនៅត្រង់ចំនុចកណ្ដាលមានប្រវែង 135mm ផងដែរ។ អ្វីដែលកាន់តែពិសេសជាងនេះទៅទៀត Dark Rock Pro 3 មានប្រវែងត្រឹមតែ 5.5’’ ដែលមានទំហំសក្តិសមល្អមក្នុងការប្រើប្រាស់ជាមួយនឹង ATX Motherboards (Micro ATX និង Mini-ITX)។៚

### លក្ខណៈទូទៅ

| | |
|---|---|
| កំពស់ | 6.6’’ |
| ទទឹង | 5.5’’ |
| ជម្រៅ | 5.9’’ (4.8’’ មិនគិតកង្ហារ) |
| កង្ហារត្រជាក់ | 120 + 135mm |
| Connectors | PWM w/Integrated Splitter ចំនួន 2 |
| Intel Sockets | 115x, 2011x, 1366, 775 |
| ទំងន់ | 1.25 Kg |






# EK-FB MONOBLOCKS
# កង្ហារត្រជាក់ថ្មីស្រឡាងពី EK WATER BLOCKS

ថ្មីៗនេះ ក្រុមហ៊ុន EK Water Block បានធ្វើការប្រកាសនូវកង្ហារត្រជាក់សម្រាប់ប្រើប្រាស់ជាមួយនឹងកុំព្យូទ័រដែលមានឈ្មោះថា EK FB Z170X Monoblock ដែលត្រូវបានរចនាយ៉ាងពិសេសសម្រាប់ប្រើប្រាស់ជាមួយនឹង Motherboards បីម៉ូដែលរបស់ម៉ាក Gigabyte ម៉ូដែល GA-Z170X-UD5 TH, GA-Z170X-Gaming 5 និង GA-170X-Gaming 7។

EK-FB Monoblock ត្រូវបានរចនាយ៉ាងពិសេសគុណភាពខ្លាំងមិនចាញ់កង្ហារត្រជាក់របស់ក្រុមហ៊ុនផ្សេងនោះទេព្រោះវាអាចដំណើរការបានយ៉ាងល្អធ្វើឱ្យម៉ាស៊ីនកាន់តែត្រជាក់ និងសំឡេងលឺស្ងាត់ថែមទៀត។ កង្ហារដ៏ថ្មីស្រឡាងនេះដំណើរការយ៉ាងរលូនជាមួយនឹង CPU ព្រមទាំង Connectors មួយចំនួនទៀតដូចជា M.2 ដែលប្រើប្រាស់នៅលើ Motherboards របស់ Gaming 5 និង Gaming 7។

ការរចនាកាន់តែទាក់ទាញជាមួយនឹងរូបរាងយ៉ាងសម្រិតសម្រាំងសម្រាប់ប្រើប្រាស់ជាមួយនឹងកុំព្យូទ័រ GIGABYTE បានធ្វើឱ្យកង្ហារត្រជាក់នេះកាន់តែលេចធ្លោរ ជាពិសេសគឺការប្រើប្រាស់ជាមួយនឹង EK-Supremacy EVO Cooling Engine ដែលដំណើរការបានយ៉ាងល្អបំផុតជាមួយនឹង Socket CPU Intel LGA-1151 និងប្រព័ន្ធភ្លើង MOSFET ថែមទៀតផង៕



# ThumbDrive Hidden Camera រូបរាងតូច សមត្ថភាពខ្លាំង



ThumbDrive Hidden Camera ជាកាមេរ៉ាសុវត្ថិភាពថ្មីដែលរចនារូបរាងតូចយ៉ាងទាន់សម័យដោយក្រុមហ៊ុន BrickHouse Security។ បើក្រឡេកមើលមួយភ្លែត វាមានរូបរាងស្រដៀងទៅនឹង USB Flash Drive (រូបរាងតូច) ប៉ុន្តែឧបករណ៍មួយនេះបានបង្កប់ភ្ជាប់ជាមួយនឹងកាមេរ៉ាដែលអាចថតរូបកម្រិតច្បាស់ដល់ទៅ 1600x1200 ភិចសែល ប្រភេទ JPG Format និងវីដេអូក្នុងកម្រិតភាពច្បាស់ 720 x 480 ភិចសែល (29fps) ប្រភេទ AVI។

មិនត្រឹមតែប៉ុណ្ណោះ វាថែមទាំងភ្ជាប់ជាមួយនឹងថ្មប្រភេទ Lithium-Polymer (ដែលអាចប្រើប្រាស់បានរយៈពេល 2 ម៉ោង)។ ThumbDrive Hidden Camera ភ្ជាប់ជាមួយនឹងរន្ធដោត microSD កាតទំហំ 32GB សម្រាប់ផ្ទុកឯកសាររូបភាពវីដេអូដែលអ្នកបានថត។ អ្វីដែលកាន់តែពិសេសជាងនេះទៀត វាបានប្រើប្រាស់នូវមុខងារ Motion Detection Recording និងប្រើប្រាស់ USB Connector ផងដែរ។

មួយវិញទៀត ThumbDrive Hidden Camera អាចថតវីដេអូបានរយៈពេល 16 ម៉ោងសម្រាប់រក្សាទុកនៅលើម៉េមូរីទំហំ 32GB នេះ។ អ្នកក៏អាចប្រើប្រាស់ឧបករណ៍នេះធ្វើជា Webcam សម្រាប់ប្រើប្រាស់នៅលើកុំព្យូទ័ររបស់អ្នកបានកាន់តែងាយស្រួល និងផ្តល់នូវរូបភាព វីដេអូកម្រិតច្បាស់បំផុត៕





## លក្ខណៈពិសេសទូទៅ

| | |
|---|---|
| កម្រិតថតវីដេអូ | 720 x 480 (29fps) |
| ប្រភេទ File វីដេអូ | AVI |
| កម្រិតថតរូបភាព | 1600 x 1200 |
| ប្រភេទ File រូបភាព | JPG |
| ទំហំម៉េមូរី | microSD កាតទំហំ 32GB |
| ការភ្ជាប់ទៅកាន់ PC | USB |

| | |
|---|---|
| ថាមពលថ្ម | Lithium-Polymer ប្រើប្រាស់បាន 2 ម៉ោង |
| កម្លាំងវ៉ុល | 3.7 – 5V |
| មុខងារកាមេរ៉ា Webcam | 32-bit Windows 2000\| Windows XP\| Windows Vista |
| វិមាត្រ | 7.6 x 2.5 cm |




# TRENDnet TEW-812DRU
## ផលិតឡើងដោយបទពិសោធន៍ពេញលេញ






ក្រុមហ៊ុន Dell បានផលិតម៉ូដែល TEW-812DRU ជាប្រភេទ router ឥតខ្សែដោយផ្គុំឡើងពី AC 1750 របស់ TRENDnet ដែលបានផលិតឡើងដោយបទពិសោធន៍ពេញលេញជាមួយល្បឿន gigabit wireless។ ការគ្រប់គ្រងទៅលើបណ្តាញឥតខ្សែចំនួនពីរគឺបណ្តុំ Wireless AC ដែលមានល្បឿន 1300 Mbps សម្រាប់ល្បឿនលឿនបំផុតនៅពេលដែល wireless ទំនេរ និងល្បឿន 450 Mbps ដែលជាបណ្តុំប្រភេទ wireless N ដើម្បីភ្ជាប់ទំនាក់ទំនងទៅកាន់ឧបករណ៍ wireless ដូចគ្នាផ្សេងទៀត។ TEW-812DRU ងាយស្រួលបំផុតក្នុងការដោះស្រាយបញ្ហាទៅតាមតម្រូវការជាច្រើនរបស់ HD streams នៅក្នុងពេលដែលរវល់ភ្ជាប់ទំនាក់ទំនងនៅផ្ទះ។

លោកអ្នកក៏អាចដោតជាមួយ USB flash ឬ NAS drive ដើម្បីចែករំលែកវីដេអូ HD និងតន្ត្រីតាមរយៈបណ្តាញ។ ផត Gigabit នៅផ្នែកខាងខ្នងនៃ router ដែលមានល្បឿនលឿនក្នុងការភ្ជាប់ទំនាក់ទំនងដោយប្រើខ្សែ។ TEW-812DRU បានភ្ជាប់មកជាមួយសមត្ថភាពជាច្រើនដូចជាប្រើផត USB 3.0 ដើម្បីចែករំលែក ហើយបានធ្វើការ encrypted ជាមុនដើម្បីសុវត្ថិភាពខ្ពស់ និងបង្កើតការដាក់ guest network ដាច់ដោយឡែកព្រមទាំងមានមួយប៊ូតុង WPS ងាយប្រើប្រាស់ជាមួយផតខ្សែ Gigabit៕

ទស្សនាវដ្ដី

# ទីក្រុងទូរស័ព្ទ

PHONE CITY MAGAZINE

MAGAZINE




## ចេញផ្សាយរៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ

### ផ្ដល់ជូននូវ:

- ម៉ូដែលទូរស័ព្ទថ្មីៗ និងរបៀបប្រើប្រាស់ទូរស័ព្ទ
- តារាងតម្លៃទូរស័ព្ទ
- អត្ថបទកម្សាន្ត យ៉ាងសម្បូរបែប
- ងាយស្រួលទាញយក តាមរយៈ Smart Phone ឬ Website

អតិថិជនមិត្តអ្នកអានទាំងអស់អាចទាញយកទស្សនាទីក្រុងទូរស័ព្ទបានដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.phonecity.com.kh ឬសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Android អាចទាញយកកម្មវិធី Phonecity បានតាមរយៈ Playstore ។

MAGAZINE


ដំណើរការរហ័ស
ចេញផ្សាយទៀងរាល់ខែ
អាចដំណើរការបានជាលក្ខណៈ Online & Offline
មើលបានគ្រប់ទីកន្លែង គ្រប់ពេល
MAGAZINE
IT City Magazine
iOS . Android . PC

# ទស្សនាវដ្ដី ទីក្រុងទូរស័ព្ទ

PHONE CITY MAGAZINE




## ចេញផ្សាយរៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ

### ផ្ដល់ជូននូវៈ

| | | | |
|---|---|---|---|
| ម៉ូដែលទូរស័ព្ទថ្មីៗ និងរបៀបប្រើប្រាស់ទូរស័ព្ទ | តារាងតម្លៃទូរស័ព្ទ | អត្ថបទកម្សាន្ត យ៉ាងសម្បូរបែប | ងាយស្រួលទាញយក តាមរយៈ Smart Phone ឬ Website |

អតិថិជនមិត្តអ្នកអានទាំងអស់អាចទាញយកទស្សនាទីក្រុងទូរស័ព្ទបានដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.phonecity.com.kh ឬសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការ Android អាចទាញយកកម្មវិធី Phonecity បានតាមរយៈ Playstore ។

MAGAZINE


ដំណើរការរហ័ស
ចេញផ្សាយរៀងរាល់ខែ
អាចដំណើរការបានជាលក្ខណៈ Online & Offline
មើលបានគ្រប់ទីកន្លែង គ្រប់ពេល
IT City Magazine
iOS . Android . PC

# បេសកកម្មសម្ងាត់ក្នុងពិភពសង្គ្រាម

## CALL OF DUTY BLACK OPS III



Call of Duty Black OPS III ត្រូវបានអភិវឌ្ឍដោយ Treyarch នឹងចែកចាយក្រោមស្លាកឈ្មោះរបស់ក្រុមហ៊ុន Activision។ ហ្គេមនេះជាផ្នែកមួយនៃស៊េរីហ្គេម Call of Duty Black OPS II (នៅឆ្នាំ 2012) ដែលត្រូវបានដំណើរការជាផ្លូវការលើប្រព័ន្ធប្រតិបត្តិការ Microsoft Windows នៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2015។

Call of Duty Black OPS III ជាសង្គ្រាមមួយដែលរំពឹងថានឹងកើតឡើងនៅ 50 ឆ្នាំក្រោយទៀតនេះ (នៅឆ្នាំ 2065)។ បច្ចុប្បន្ននេះ ពិភពលោកទាំងមូលគឺកាន់តែបង្កើននូវសុវត្ថិភាព និងការការពារកាន់តែខ្លាំងពីក្រុមចារកម្មសម្ងាត់។ អ្វីៗដែលធ្លាប់តែសុវត្ថិភាពប្រែក្លាយទៅជាកន្លែងដែលពោរពេញដោយសង្គ្រាមដ៏ញាក់សាច់។ ការធ្វើសង្គ្រាមនៅក្នុងហ្គេមនេះ តួអង្គនីមួយៗបាញ់ប្រហារគ្នាដូចជារឿងហូលីវូដអញ្ចឹង។

ហ្គេមបាញ់ប្រហារមួយនេះត្រូវបានអភិវឌ្ឍជាមួយនឹងទេសភាពផ្សេងៗពីគ្នាជាច្រើនវគ្គដ៏អស្ចារ្យ។ ដើម្បីឈ្នះការប្រកួតនេះកាន់តែលឿន អ្នកអាចធ្វើការលេងជាក្រុមដែលមានសមាជិកដល់ទៅ 4 នាក់។ អ្នកអាចធ្វើការកំណត់ចំនួនកងទ័ពដែលអ្នកត្រូវការ ឬការបង្កើតក្រុមសម្ងាត់មួយដើម្បីបំពេញភារកិច្ចទៅតាមវគ្គនីមួយៗ។ សូមរីករាយជាមួយនឹងវគ្គថ្មី Call of Duty Black OPS III នេះ៕

## ព័ត៌មានពីហ្គេម

អ្នកអភិវឌ្ឍហ្គេម ៖ Treyarch អ្នកចែកចាយ៖ Activision

ប្រភេទហ្គេម ៖ Action| Adventure

ថ្ងៃចេញផ្សាយ ៖ 6 វិច្ឆិកា 2015

ប្រព័ន្ធប្រតិបត្តិការ ៖ Microsoft Windows

## តម្រូវការប្រព័ន្ធ

CPU : Intel® Core™ i3-530 @ 2.93 GHz | AMD Phenom™ II X4 810 @ 2.60 GHz

RAM : 6 GB RAM

OS : Windows 7 64-Bit | Windows 8 64-Bit | Windows 8.1 64-Bit

HDD : 60 GB

Graphic : NVIDIA® GeForce® GTX 470 @ 1GB | ATI® Radeon™ HD 6970 @ 1GB







# ដំណើរផ្សងព្រេងស្វែងរកមាស



Minecraft Story Mode ត្រូវបានអភិវឌ្ឍ និងចែកចាយក្រោមស្លាកឈ្មោះរបស់ក្រុមហ៊ុន Telltale Games ។ Episode 2 ជាវគ្គថ្មីរបស់ហ្គេម Minecraft Story Mode ត្រូវបានដំណើរការជាផ្លូវការលើប្រព័ន្ធប្រតិបត្តិការ Microsoft Windows នៅថ្ងៃទី 27 តុលា 2015 ។ Episode 2 នេះត្រូវបានដាក់ឱ្យទាញយកក្រោយ Episode 1 ដាក់ដំណើរការបានតែពីរសប្តាហ៍ប៉ុណ្ណោះ។

នៅក្នុងវគ្គទីពីរនេះ Assembly Required គឺជាពេលដែលបាត់បង់នូវ Heroes ហើយព្យុះ Wither ក៏កំពុងតែវាយបក់មកកាន់តែកៀកផងដែរ។ Jesse ហើយមិត្តជាច្រើនរបស់គាត់កំពុងតែស្វែងរកនូវតាកតិច វិធីសាស្ត្រថ្មីៗដើម្បីធ្វើការស្វែងរកអាណាចក្ររបស់ Magnus និង Ellegaard។ នៅក្នុងវគ្គទីពីរនេះ ក្រាហ្វិករបស់ Minecraft Story Mode Episode 2 គឺកាន់តែទាក់ទាញ សំឡេងកាន់តែកន្ត្រាក់អារម្មណ៍ និងជក់ចិត្តជាទីបំផុត។

លក្ខណៈពិសេសថ្មីជាច្រើនរបស់ហ្គេម Minecraft Story Mode Episode 2 នឹងធ្វើឱ្យអ្នកទទួលបាននូវបទពិសោធន៍ដ៏អស្ចារ្យដែលមិនធ្លាប់បានជួបពីមុនមក។ វគ្គពីរនេះមានដំណើរផ្សងព្រេងយ៉ាងអស្ចារ្យជាច្រើនវគ្គ និង 5 តំបន់ផ្សេងៗគ្នា។ មិនត្រឹមតែប៉ុណ្ណោះ អ្នកត្រូវធ្វើការសម្រេចចិត្តឱ្យបានម៉ត់ចត់ ដើម្បីធ្វើដំណើរទៅរកអាណាចក្រទាំងនោះឱ្យឃើញ។ ក្រាហ្វិកក៏កាន់តែទាក់ទាញជាងមុន សំឡេងក៏កាន់តែរំភើបញាប់ញ័រទៀត។ តើនៅរង់ចាំអ្វីទៀត តោះទាញយកទាំងអស់គ្នា៕



## ព័ត៌មានពីហ្គេម

| | |
|---|---|
| អ្នកអភិវឌ្ឍហ្គេម | ៖ Telltale Games |
| អ្នកចែកចាយ | ៖ Telltale Games |
| ប្រភេទហ្គេម | ៖ Adventure |
| ថ្ងៃចេញផ្សាយ | ៖ 27 តុលា 2015 |
| ប្រព័ន្ធប្រតិបត្តិការ | ៖ Microsoft Windows |

## តម្រូវការប្រព័ន្ធ

| | |
|---|---|
| CPU | : Core 2 Duo 2GHz |
| RAM | : 3 GB RAM |
| OS | : Windows XP Service Pack 3 |
| HDD | : 3 GB |
| Graphic | : ATI \| NVIDIA card w/512 MB RAM |

# កម្មវិធីថ្មីៗ New Software



## Driver Genius Professional អ្នកជំនាញស្វែងរក Driver

Driver Genius Professional គឺជា Driver Tool ដ៏អស្ចារ្យមួយដែលអាចធ្វើការស្វែងរកនូវ Driver ដែលអ្នកត្រូវការសម្រាប់ប្រើប្រាស់ក្នុងកុំព្យូទ័ររបស់អ្នកបានយ៉ាងងាយស្រួលបំផុត។ កម្មវិធីមួយនេះអាចធ្វើការតម្លើងនូវ Driver របស់អ្នក Up-to-date និងមានមុខងារ Back-up ហើយ Restore នូវ Drivers របស់អ្នកបានក្នុងករណីដែលប្រព័ន្ធ System គាំង ឬនៅពេលដែលធ្វើការ Upgrade ទៅលើប្រព័ន្ធ System។ Driver Genius នេះថែមទាំងអាចធ្វើការវិភាគទៅលើ Drivers នៅក្នុងប្រព័ន្ធកុំព្យូទ័ររបស់អ្នកបានយ៉ាងរលូន ពិសេសការ Upgrade Driver ចេញពី Database ដែលមានចំនួនច្រើនជាង 60,000 Drivers ។ Driver នៅក្នុងកម្មវិធីនេះមានដូចជា Driver របស់ Motherboards, Sound Cards, Network Cards, Modems, Monitors, Mice, Keyboards, Digital Cameras, Video Capture Cards និងជាច្រើនទៀត។ អ្វីដែលកាន់តែងាយស្រួលនោះគឺប្រើប្រាស់នូវ Wizard មានបី ៣ ដំណាក់កាលៈ ស្កេន (Scan) ទាញយក (Download) និងតម្លើង (Install)៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 15 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## CyberLink PowerDVD 15 Ultra អស់បញ្ហាក្នុងការចាក់ចម្រៀង វីដេអូ




CyberLink PowerDVD 15 Ultra ជាកម្មវិធីដ៏អស្ចារ្យសម្រាប់ធ្វើការចាក់សំឡេង និងវីដេអូស្គាល់ច្រើន Formats ដោយដំណើរការយ៉ាងរលូនជាមួយនឹងកម្រិត frame rate ដល់ទៅ 120/240 fps ដែលប្រសើរជាងកម្មវិធីចាក់វីដេអូផ្សេងៗជាច្រើនទៀត។ អ្នកអាចធ្វើការរក្សាទុកនូវវីដេអូ រូបភាព តន្ត្រី និងឯកសារជាច្រើនទៀតនៅលើ CyberLink Cloud បានទំហំដល់ទៅ 20GB ។ មិនត្រឹមតែប៉ុណ្ណោះ កម្មវិធី CyberLink Power DVD 15 Ultra ថែមទាំងបញ្ចូលនូវកម្មវិធី Power Media Player និង PowerDVD Remote តាមកម្មវិធីទូរស័ព្ទបានថែមទៀតផង។ អ្នកអាចធ្វើការចាក់វីដេអូ ចម្រៀង ឬមើលរូបភាពនៅលើ YouTube ឬ Facebook បានថែមទៀត៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 141 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Aiseesoft PDF to Image Converter បម្លែង PDF ទៅជារូបភាព




Aiseesoft PDF to Image Converter មានសមត្ថភាពខ្ពស់ក្នុងការបម្លែងនូវឯកសារប្រភេទ PDF របស់អ្នកទៅជារូបភាពជាច្រើន Formats តាមតម្រូវការដែលមានកម្រិតច្បាស់ខ្ពស់បំផុត។ ឧទាហរណ៍ អ្នកអាចធ្វើការបម្លែងឯកសារ PDF ជាប្រភេទ TIFF, JPEG, PNG, GIF, BMP, TGA, PPM និង JPEG2000។ មុនពេលដែលអ្នកធ្វើការបម្លែងនូវឯកសារ PDF កម្មវិធី Aiseesoft PDF to Image Converter នឹងជួយលោកអ្នកក្នុងការជ្រើសរើសនូវទំព័រពីចន្លោះត្រឹមណាដល់ត្រឹមណា ឬសន្លឹកណាមួយដែលអ្នកចង់បាន។ រាល់រូបភាពដែលអ្នកបានធ្វើការបម្លែងជាមួយនឹងកម្មវិធីនេះអាចបើកមើលបាននៅលើគ្រប់ Platforms ទាំងអស់៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 14 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Animated Wallpaper Maker អ្នកជំនាញបង្កើតនូវ Wallpaper មានចលនា




Animated Wallpaper Maker គឺជាកម្មវិធីសម្រាប់ធ្វើការបង្កើតនូវ Animation Effects មានចលនាជាច្រើនប្រភេទសម្រាប់ធ្វើការរៀបចំប្រើប្រាស់នៅលើ Desktop Background នៅលើកុំព្យូទ័ររបស់អ្នក។ វាមានភ្ជាប់ជាមួយនឹងមុខងារ Editor ដែលអនុញ្ញាតឱ្យអ្នកធ្វើការបន្ថែមនូវ Animation ដើម្បីបង្កើតជា Wallpaper ដ៏ស្រស់ស្អាតសម្រាប់ប្រើប្រាស់នៅលើ Windows (ទ្រទ្រង់នូវគ្រប់ Formats រូបភាព)។ បន្ទាប់ពីធ្វើការបង្កើតនូវរូបភាពមានចលនារួច អ្នកអាចធ្វើការបិទ ឬបើក Animation បានកាន់តែងាយស្រួលបំផុតទៅតាមចិត្តរបស់អ្នក៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 21 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## My Lockbox Pro អ្នកឯកទេសការពារទិន្នន័យ

My Lockbox Pro ជាកម្មវិធីដែលមុខងារកាន់តែពិសេសក្នុងការលាក់ ចាក់សោរ ឬការការពារលេខសម្ងាត់របស់Folders នៅលើកុំព្យូទ័ររបស់អ្នក។ អ្នកអាចធ្វើការប្រើប្រាស់នូវកម្មវិធី My Lockbox ដើម្បីធ្វើការលាក់នូវឯកសារផ្ទាល់ខ្លួនរបស់អ្នកពីសំណាក់ Hacker ឬអ្នកដែលលួចប្រើប្រាស់កុំព្យូទ័ររបស់អ្នក។ នៅពេលដែលអ្នកចាក់សោររួចរាល់ហើយ ឯកសាររបស់អ្នកនឹងមិនអាចចូលមើលបានទាំងតាមប្រព័ន្ធ Network ឬការ Remote ជាដើម។ ប្រសិនបើអ្នកពិតជាខ្លាចការលបលួចមើលទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក សូមប្រើប្រាស់នូវកម្មវិធីដ៏អស្ចារ្យនេះ។




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 7 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## EaseUS Partition Master ជំនាញក្នុងការគ្រប់គ្រង Partition

EaseUS Partition Master គឺជាកម្មវិធី All-in-one Partition Magic ដែលមានមុខងារក្នុងការរៀបចំនូវទំហំ Disk របស់កុំព្យូទ័ររបស់លោកអ្នកបានយ៉ាងងាយស្រួលបំផុត។ កម្មវិធីនេះអនុញ្ញាតឱ្យអ្នកធ្វើការពង្រីកនូវទំហំ Partition ( ទំហំ System Drive ) ការរៀបចំទំហំ Disk Space ការបង្កើនល្បឿននៅលើ MBR ឬ GPT Disk បានថែមទៀត។ លក្ខណៈពិសេសៗរបស់កម្មវិធីនេះគឺ ការបង្រួមទំហំ Partition ការផ្លាស់ទី Partition ការពង្រីក Partition Drive ការចម្លង Partition ការធ្វើការ Merge Partition ការបំបែក Split Partition ការបម្លែង Dynamic Disk និងការ Recover Partition ជាដើម។







| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 30 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## BlueStacks App Player កាន់តែងាយស្រួលលេងកម្មវិធី ឬហ្គេម Android

BlueStacks App Player គឺជា Tool មួយដ៏អស្ចារ្យដែលអនុញ្ញាតឱ្យអ្នកអាចដំណើរការនូវកម្មវិធី Mobile Apps ឬហ្គេមទូរស័ព្ទនៅលើអេក្រង់ Full Screen នៅលើ Browser របស់កុំព្យូទ័រ ឬ Mac របស់អ្នកបានយ៉ាងរលូន។ កម្មវិធី BlueStacks អាចធ្វើការតភ្ជាប់ជាមួយនឹងកម្មវិធីបណ្តាញសង្គម Facebook ឬ Twitter នៅលើ Platforms ជាច្រើនបានផ្សេងគ្នា។ ការដំណើរការកម្មវិធី Android Apps ទាំងនេះនៅលើកុំព្យូទ័ររបស់អ្នកគឺកាន់តែងាយស្រួល ពិសេសអ្នកអាចធ្វើការចូលទៅកាន់គណនី Google Play ដើម្បីធ្វើការទាញយកនូវកម្មវិធី ឬហ្គេមដែលអ្នកពេញចិត្ត។ វាពិតជាងាយស្រួល និងអស្ចារ្យណាស់៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 261 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## AirRadar អ្នកជំនាញស្វែងរកប្រព័ន្ធ Wi-Fi

តើអ្នកកំពុងតែស្វែងរកនូវប្រព័ន្ធ Wi-Fi ឥតគិតថ្លៃនៅពេលធ្វើដំណើរថ្ងៃវិស្សមកាល ឬកន្លែងណាដែលនៅឆ្ងាយពីតំបន់ដែលអ្នកកំពុងតែស្នាក់នៅ? តើអ្នកភ័យព្រួយទេ ប្រសិនបើកន្លែងដែលអ្នកបានទៅគ្មានប្រព័ន្ធ Wi-Fi? AirRadar ជាកម្មវិធីមួយដែលបំពាក់នូវបច្ចេកវិទ្យា GPS ថ្មីដែលអាចធ្វើការស្កេននូវទីតាំងរបស់ប្រព័ន្ធ Wi-Fi នឹងបង្ហាញនៅលើផែនទី។ កម្មវិធី AirRadar នឹងធ្វើការ Update ដោយស្វ័យប្រវត្តិនូវទីតាំងនៅបណ្តាញដែលមានប្រព័ន្ធ Wi-Fi ខ្លាំង និងល្អជាងគេបំផុត។ ប្រព័ន្ធ Wi-Fi ដែលអាចប្រើប្រាស់បានគឺលោតពណ៌ខៀវ ចំណែក Wi-Fi ដែលបិទគឺមានពណ៌ក្រហម។ តោះសាកល្បងប្រើប្រាស់កម្មវិធីនេះទាំងអស់គ្នាមើល តើវាអាចធ្វើអ្វីបានខ្លះ?




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 17 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |



អ្នកអភិវឌ្ឍហ្គេម៖ Dovetail Games អ្នកចែកចាយ៖ Dovetail Games
ប្រភេទហ្គេម៖ Simulation| Sports ថ្ងៃចេញផ្សាយ៖ 2 វិច្ឆិកា 2015

**តម្រូវការប្រព័ន្ធ**

CPU : Quad-Core 3.0 GHz RAM : 8 GB RAM
OS : Windows® 7 64bit | 8 64bit HDD : 2 GB
Graphic: Graphics Card (2 GB Video RAM) | Nvidia Geforce GTX 660

# កំពូលជើងឯក ស្ទូចត្រីពិភពលោក

តើអ្នកពិតជាកំពូលអ្នកស្ទូចត្រីមែនដែរឬទេ? តើអ្នកចង់ប្រកួតប្រជែងស្នាដៃរបស់អ្នកជាមួយនឹងមនុស្សនៅជុំវិញពិភពលោកមែនឬទេ? នៅក្នុងហ្គេម Euro Fishing អ្នកនឹងត្រូវជួបនូវបទពិសោធន៍ថ្មីក្នុងការស្ទូចត្រីនៅលើបឹងធំៗជាច្រើននៅលើពិភពលោកពិសេសនៅទ្វីបអ៊ឺរ៉ុប ហើយអ្នកពិតជាអាចបង្ហាញពីសមត្ថភាពថ្វីដៃនៃការស្ទូចត្រីរបស់អ្នកបានថែមទៀតផង។ ហ្គេមនេះផ្តល់នូវភាពរីករាយមិនមែនសម្រាប់តែអ្នកស្ទូចត្រីអាជីពនោះទេ ប៉ុន្តែសម្រាប់អ្នកដែលមិនធ្លាប់ស្ទូចត្រីក៏មានអារម្មណ៍ប្លែក គឺមិនចង់ឈប់លេងហ្គេមស្ទូចត្រីនោះទេ។

សម្រាប់អ្នកដែលចាប់ផ្តើមស្ទូចត្រីជាលើកដំបូងហ្គេមនេះបានបង្រៀនអ្នកពីការស្ទូចត្រីតាមជំហ៊ានដំបូងរហូតដល់ការស្ទូចត្រីលក្ខណៈអាជីព។ អ្វីដែលធ្វើឱ្យអ្នករីករាយបំផុតគឺការស្ទូចត្រីនៅក្នុងទន្លេដ៏ស្រស់ស្អាត St John's Lake និង Diggers Lake។ Euro Fishing បំពាក់នូវ AI ដ៏ឆ្លាតវៃបំផុតដែលធ្វើឱ្យការស្ទូចត្រីកាន់តែប្រកួតប្រជែង និងស្វិតស្វាញបំផុត។ អ្នកអាចធ្វើការប្រកួតប្រជែងជាមួយនឹងមិត្តភក្តិរបស់អ្នកដើម្បីដឹងថា តើអ្នកណាពិតជាកំពូលអ្នកស្ទូចត្រីពិតប្រាកដមែន? សូមធានាថា ក្រាហ្វិករបស់ហ្គេមនេះពិតជាស្រស់ស្អាត និងទាក់ទាញបំផុត៕

# ជើងឯកប្រណាំងម៉ូតូធំដ៏ស្ទិតស្នាញ

# MX vs ATV SUPERCROSS ENCORE



អ្នកអភិវឌ្ឍហ្គេម៖ Rainbow Studios | Nordic Games អ្នកចែកចាយ៖ Nordic Games

ប្រភេទហ្គេម៖ Racing | Simulations | Sports ថ្ងៃចេញផ្សាយ៖ 27 តុលា 2015

**តម្រូវការប្រព័ន្ធ**

CPU : Intel® Core™ 2 Duo @ 1.8Ghz | AMD Athlon 64 X2 HDD : 5 GB

OS : Windows® Vista | Windows® 7 | Windows® 8 RAM : 2 GB Graphic: Intel HD 3000 | NVIDIA GeForce GTS 240 (1GB VRAM) | ATI Radeon HD 4600 (1GB VRAM)

តើលោកអ្នកពិតជាកំពូលអ្នកប្រណាំងម៉ូតូធំមែនទេ? តើអ្នកជឿជាក់ទៅលើសមត្ថភាពប្រណាំងម៉ូតូធំរបស់អ្នកមែនដែរឬទេ? MX vs ATV Supercross Encore ជាប្រភេទហ្គេមប្រណាំងម៉ូតូធំថ្មីដ៏ទាក់ទាញ និងមានក្រាហ្វិកស្រស់ស្អាតបំផុត។ នៅក្នុងវគ្គប្រណាំងម៉ូតូធំនេះ ការប្រណាំងសុទ្ធតែមានចាប់ពីពីរជុំឡើងទៅ ជាពិសេសគឺវគ្គថ្មី Rhythm Racing Mode ដែលការប្រណាំងម៉ូតូត្រូវមើលផែនទីដើម្បីយកឈ្នះដៃគូប្រកួត។ សំឡេង និងក្រាហ្វិកត្រូវបានបន្ថែមកាន់តែពិរោះរណ្តំចិត្ត ទាក់ទាញបំផុត។

ចំណែកនៅត្រង់វគ្គ Free Ride Mode អ្នកត្រូវធ្វើការប្រណាំងជាមួយនឹងជើងឯកប្រណាំងច្រើនជាង 60 នាក់ទៀតនៅលើទីលាន។ រូបភាពសុទ្ធតែជាប្រភេទ 3D អមជាមួយនឹងសំឡេងប្រណាំងសន្ធឹកពេញទីលានទាំងមូលធ្វើឱ្យអារម្មណ៍របស់អ្នកព្រឺព្រួចបំផុត។ ប្រសិនបើអ្នកជ្រើសរើសនូវវគ្គ Online Mode អ្នកអាចលេងបានគ្នាដល់ទៅ 12 នាក់ក្នុងពេលតែមួយ៕



# ស្វែងយល់ពីគន្លឹះផ្សេងៗ ក្នុងការប្រើប្រាស់កុំព្យូទ័រ

## របៀបពិនិត្យមើលនូវ Computer Specifications

## វិធីសាស្ត្រក្នុងការបិទ Pop-ups នៅក្នុង Internet Explorer និង Mozilla Firefox

## របៀបនៃការបង្កើត ឬចែកទីតាំងសម្រាប់ផ្ទុក ទិន្នន័យរបស់អ្នក

# របៀបពិនិត្យមើលនូវ Computer Specifications




ប្រសិនបើអ្នកចង់តំឡើងកម្មវិធីថ្មីណាមួយដល់កុំព្យូទ័ររបស់អ្នក អ្នកចាំបាច់ត្រូវដឹងថាតើកុំព្យូទ័ររបស់អ្នកមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ឱ្យកម្មវិធីមួយនោះដំណើរការដោយគ្មានភាពរអាក់រអួលបាន ឬអត់។ វិធីសាស្ត្រខាងក្រោមនេះនឹងបង្ហាញប្រាប់អ្នកអំពីរបៀបនៃការបង្ហាញព័ត៌មានស្តីអំពីសមត្ថភាព របស់កុំព្យូទ័ររបស់អ្នក៖

## វិធីសាស្ត្រទីមួយ: សម្រាប់ Windows

- បើក System window

ដើម្បីធ្វើដូចនេះបានចូរអ្នកចុចគ្រាប់ចុចផ្គួបគ្នារវាង Windows key + Pause ឬ click mouse ខាងស្តាំលើ This PC ។



- ស្វែងរក system specs របស់កុំព្យូទ័ររបស់អ្នក

នៅក្នុងដំណាក់កាលនេះអ្នកអាចទទួលបានព័ត៌មានស្តីអំពី Processor ប្រព័ន្ធ Memory (RAM) និង System type ។



- ត្រួតពិនិត្យមើល installed graphics card នៃកុំព្យូទ័ររបស់អ្នក

ដើម្បីចូលទៅកាន់ទីតាំងនេះបានអ្នកចាំបាច់ចុចលើពាក្យថា Device Manager ពីផ្ទាំងខាងលើ រួចចុចពីលើជម្រើស Display adapters ដូចរូបនោះ graphics card ដែលបានតំឡើងហើយនឹងបង្ហាញឡើង។




- ឆែកមើលទំហំ hard disk ដែលនៅទំនេរសម្រាប់តំឡើងកម្មវិធីរបស់អ្នក

នៅក្នុងពេលនេះចូរអ្នកបើក My Computer ឬ This PC បន្ទាប់មកចូរអ្នក click mouse ខាងស្តាំលើ drive C បន្ទាប់មកទៀតជ្រើសរើសយកពាក្យថា Properties ធ្វើដូចនេះអ្នកនឹងទទួលបានព័ត៌មានស្តីអំពីទំហំ hard disk space ដែលនៅសល់ជាក់ជាមិនខាន។




# វិធីសាស្ត្រក្នុងការបិទ Pop-ups នៅក្នុង Internet Explorer និង Mozilla Firefox

Pop-ups គឺជាផ្ទាំងដែលបានបង្ហាញឡើងដោយស្វ័យប្រវត្តិអំពីព័ត៌មានផ្សេងៗ ឬជាការផ្សព្វផ្សាយផ្សេងៗជាដើម ដែលរំខានដល់អ្នកខ្លាំងបំផុតនៅពេលកំពុងប្រើប្រាស់។ ពេលខ្លះពួកវាផុសចេញមកបាំងការបង្ហាញរបស់យើងធ្វើឱ្យយើងមានអារម្មណ៍ធុញថប់ជាខ្លាំង ប៉ុន្តែកុំបារម្ភយើងអាច Block Pop-ups ទាំងនេះបានដោយអនុវត្តតាមជំហានខាងក្រោម៖

## ការ Blocking Pop-ups នៅលើ Internet Explorer 10

បើកកម្មវិធី Internet Explorer ដោយអ្នកគ្រាន់តែ double click លើវាជាការស្រេច។




ស្វែងរកប៊ូតុង “Settings” ដែលស្ថិតនៅកែងខាងស្តាំនៃផ្ទាំង window បន្ទាប់មកចូរចុចលើវាដើម្បីបង្ហាញជម្រើសជាច្រើនទៀត។



ជ្រើសរើសយកជម្រើស "Internet Options." ។




Click លើ Privacy tab ដែលស្ថិតនៅផ្នែកខាងលើនៃ window។




Click លើប្រអប់ check box ដែលមានពាក្យថា "Turn on Pop-up Blocker." ធ្វើដូចនេះអ្នកនឹងអាច Block pop-up នៅលើ Internet Explorer បាន។




## ការ Blocking Pop-ups នៅលើ Mozilla Firefox

បើកកម្មវិធី Mozilla Firefox browser ដោយការ clicking លើរូបតំណាងរបស់វាដែលមាននៅលើ desktop របស់អ្នក។




Click លើប៊ូតុង "Menu" ដែលមានទីតាំងស្ថិតនៅជ្រុងខាងស្តាំផ្នែកខាងលើនៃផ្ទាំង window ដើម្បីធ្វើការបង្ហាញជម្រើសផ្សេងទៀតសម្រាប់អ្នក។




ស្វែងរកជម្រើស "Options" ហើយបន្ទាប់មក click លើវាជាការស្រេច។



ចុច Click លើ Content tab។




ដើម្បីសម្រេចបានលទ្ធផលចុច Click លើប្រអប់ check box ដែលមានពាក្យថា "Block pop-up windows." នោះអ្នកនឹងចាប់ផ្តើម blocking pop-up windows បានសម្រេច។




# របៀបនៃការបង្កើត ឬចែកទីតាំងសម្រាប់ផ្ទុក ទិន្នន័យរបស់អ្នក

ការធ្វើ Disk partitioning គឺជាការចែក hard disk ទៅជាផ្នែកតូចៗ។ ធ្វើដូចនេះអ្នកអាចដាក់ទិន្នន័យ របស់ operating system ឱ្យនៅដាច់ដោយឡែកពីគ្នាពីទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកចៀសវាងនូវការខូចខាត ឬបាត់បង់ដោយថាហេតុ។

## ជំហានក្នុងការធ្វើ Disk partitioning

បើកជម្រើស Computer Management។ ដើម្បីបើកវាដំបូងចូរអ្នកចុច Start menu បន្ទាប់មកវាយពាក្យ ថា "Computer Management" នៅក្នុងប្រអប់ស្វែងរក ហើយចុចគ្រាប់ Enter។




ធ្វើការ Select លើពាក្យ Disk Management ដូចរូបខាងក្រោមនេះ។




នេះជាដំណាក់កាលដែលអ្នកបង្កើតទំហំឲ្យ partition ថ្មី ដោយចាប់ផ្តើមពីការចុច mouse ខាងស្តាំលើ partition ណាមួយដែលអ្នកចង់កំណត់ទំហំវាឡើងវិញ បន្ទាប់មកចូរជ្រើសរើសយក ពាក្យថា Shrink Volume។ ក្នុងករណីដែលអ្នកឃើញ partition ដែលមានឈ្មោះថា System Reserved អ្នកមិនគួរប៉ះពាល់លើ partition មួយនេះទេ។




## Shrink the drive

វាយបញ្ចូលទំហំណាមួយដែលអ្នកត្រូវការដែលទំហំនោះគិតជា mega-bytes (1000 MB = 1GB)។ បន្ទាប់ពីធ្វើការកំណត់រួចរាល់ហើយចូរចុចលើប៊ូតុង Shrink។ ចូរចងចាំថា អ្នកមិនអាចកំណត់ទំហំ របស់វាឱ្យធំជាងទំហំដែលវាមាននោះទេ ដូចនេះអ្នកត្រូវកំណត់ទំហំឲ្យតូចជាងទំហំដើម ដើម្បីផ្តល់ទំហំដែលនៅសល់សម្រាប់ partition ថ្មី។




## បង្កើត volume ថ្មីមួយ

នៅក្នុងពេលនេះអ្នកនឹងឃើញ partition ដែលមិនទាន់បានប្រើប្រាស់នៅឡើយ។ ចូរអ្នក click mouse ខាងស្តាំលើ partition ហើយជ្រើសរើសយកពាក្យ New Simple Volume option។




ពេលនេះអ្នកនឹងឃើញមានផ្ទាំងមួយបានបង្ហាញឡើង ចូរ Click ប៊ូតុង Next ដើម្បីបន្ត។




វាយបញ្ចូលទំហំសម្រាប់ partition ថ្មីបន្ទាប់មកចុចប៊ូតុង Next។



ផ្ដល់ឈ្មោះ និងឈ្មោះតួអក្សរផងដែរដល់ volume នោះ ហើយចុចប៊ូតុង «Next» ដើម្បីបន្តការតំឡើង។




## ការកំណត់សម្រាប់ volume ដើម្បីអាចប្រើប្រាស់វាបាន

Click លើជម្រើស Format this volume with the following settings :

- សម្រាប់ File System ចូរជ្រើសរើស NTFS
- សម្រាប់ Allocation unit size ចូរជ្រើសរើស Default
- សម្រាប់ Volume Label ចូរសរសេរឈ្មោះថ្មីដែលអ្នកចង់ដាក់ឲ្យ drive របស់អ្នក

ចុច Click ប្រអប់ Perform a quick format បន្ទាប់មកចូរ click លើប៊ូតុង Next។




អ្នកបានបញ្ចប់ក្នុងការបង្កើត volume ថ្មីមួយ។ ចូរចុចប៊ូតុង Finish ដើម្បីបញ្ចប់ការតំឡើង។




អ្នកនឹងឃើញមានផ្ទាំងមួយផុសឡើង ចូរចុចលើប៊ូតុង Format disk ហើយបន្ទាប់មកចូរ click លើប៊ូតុង Start រួច click លើប៊ូតុង OK ជាការស្រេច។




ពិនិត្យមើល new volume៕





# មេរោគកុំព្យូទ័រ 8 ប្រភេទដែលត្រូវប្រុងប្រយ័ត្នបំផុត !

នៅពេលមេរោគចូលលុកលុយប្រព័ន្ធប្រតិបត្តិការ ( Operating System ) កុំព្យូទ័រវានឹងធ្វើឱ្យកុំព្យូទ័រដើរយឺត បាត់ឯកសារ ឬឈប់ដំណើរការតែម្តង។ អ្នកស្រាវជ្រាវមួយចំនួនបានចំណាយពេលជាច្រើនដើម្បីកំណត់ប្រភេទមេរោគកុំព្យូទ័រក៏ដូចជាឯកសារគំរាមកំហែង (threats) អំពីដើមចមនៃការកកើត ឥទ្ធិពល និងរបៀបឆ្លង។ ផលប៉ះពាល់ក្រោយពីមេរោគឆ្លងគឺអាស្រ័យទៅតាមប្រភេទខ្លាំងឬខ្សោយ។ ខាងក្រោមនេះ គឺជាមេរោគកុំព្យូទ័រ ៨ប្រភេទដែលអ្នកប្រើកុំព្យូទ័រ ត្រូវប្រុងប្រយ័ត្នបំផុត៖

## Boot Sector Virus

ពាក្យ "boot sector" គឺជាឈ្មោះដែលមានដើមកំណើតមកពី MS-DOS ត្រូវបានប្រើនៅក្នុងដំណាក់កាលនៃការចាប់ផ្តើមដំណើរការប្រព័ន្ធប្រតិបត្តិការកុំព្យូទ័រ។ ជាធម្មតានៅក្នុងកុំព្យូទ័រទំនើប ត្រូវបានគេហៅថា "master boot record" ដែលជាកន្លែងផ្ទុកទិន្នន័យ ( sector ) ដំបូងបង្អស់នៅលើឧបករណ៍ផ្ទុកទិន្នន័យ ត្រូវបែងចែកតំបន់ផ្សេងគ្នា ( partition )។

Boot Sector គឺជាផ្នែកនៃឧបករណ៍ផ្ទុកទិន្នន័យ ដែលមានទីតាំងនៅលើ RAM។ ដោយសារវាផ្សាំខ្លួននៅក្នុងដំណាក់កាលចាប់ផ្តើមដំណើរការ (boot) នៃប្រព័ន្ធប្រតិបត្តិការ ដូច្នេះវាងាយវាយប្រហារចូលដល់ប្រព័ន្ធចាប់ផ្តើមដំបូងណាស់ ( System Startup )។

## Browser Hijacker

ជាពពួកមេរោគកុំព្យូទ័រដែលវាយប្រហារកម្មវិធីបើកគេហទំព័រ (Internet Browser)។ ជាទូទៅវាស្ថិតក្នុងទម្រង់ឯកសារកម្មវិធី (application) នៅពេលគេចុចទាញយក ( download ) ពីវែបសាយមានមេរោគ ( malicious website )។ រោគសញ្ញាវា គឺនាំអ្នកប្រើចូលទៅកាន់គេហទំព័រណាមួយជាក់លាក់ដែលជាល្បិចដើម្បីបង្កើនចំនួនចរាចរណ៍ ( traffic ) ច្រើននៅលើគេហទំព័រទាំងនោះ ក្នុងបំណងទាញយកផលប្រយោជន៍ជាប្រាក់ចំណូលជាដើម។



## File Infector Virus

ជាប្រភេទមេរោគ malware ដែលឆ្លងតាមឯកសារដំណើរការបាន (executable file (*.exe, *.com)) ឬធ្វើឱ្យខូចខាតឯកសារ ឬរហូតមិនអាចប្រើបានតែម្តង។ មេរោគនេះនឹងសរសេរកូដជាន់ពីលើ ឬបញ្ចូលកូដដែលធ្វើឱ្យខូចទៅក្នុងឯកសារ executable file។ ប្រភេទមេរោគនេះ មួយចំនួនធ្វើឱ្យខូចប្រព័ន្ធដំណើរការបានទៀតផង រួមមាន Windows, Macintosh និង Unix ជាដើម។ មិនត្រឹមតែ វាតត្បាតនៅលើកុំព្យូទ័រទេ តែថែមទាំងលុកលុយចូលដល់ប្រព័ន្ធបណ្តាញ (Network) ទៀតផង។ មេរោគដែលស្ថិតក្នុងប្រភេទនេះ ឈ្មោះ Win32.Sality.BK គឺជា file-infecting virus ដែលល្បីបំផុតក្នុងចំណោម malware infection ទាំង ១0 ប្រចាំឆ្នាំ២0១១-២0១២។



## Macro Virus

Macro Virus គឺជាប្រភេទមេរោគកុំព្យូទ័រមួយ ផ្តល់ផលប៉ះពាល់ចេញជារោគសញ្ញារំខានផ្សេងៗដោយស្វ័យប្រវត្តិនៅពេលចាប់ផ្តើមដំណើរការកម្មវិធី (application)។ វាកើតចេញពីភាសាកម្មវិធី Macros ភាគច្រើនមាននៅលើកម្មវិធីការិយាល័យរបស់ Microsoft ជាក់ស្តែង MS Excel តែអាចត្រូវបានគេបង្កើតជាមេរោគបាន។ ទោះជាយ៉ាងណា កម្រិតបង្ករោគនៃ Macro Virus នេះមានទាប គឺអាចត្រឹមតែធ្វើឱ្យ error បន្តិចបន្តួចប៉ុណ្ណោះ។ ដំណើរការបំបែកខ្លួនរបស់មេរោគនេះ គឺធ្វើឡើងភាគច្រើនតាមសារអេឡិចត្រូនិក ឬអ៊ីមែល ឧទាហរណ៍៖ មេរោគ Melissa កាលពីឆ្នាំ១៩៩៩។



## Multipartite Virus

ខណៈដែលមេរោគមួយចំនួនសប្បាយនឹងពង្រីកខ្លួនតាមវិធីសាស្ត្រតែមួយ ឬវាយលុកចូលក្នុង ឯកសារតែមួយមុខនោះ Multipartite Virus នឹងបំបែកខ្លួនតាមរបៀប ផ្សេងៗគ្នាជាច្រើន ហើយបង្ករោគសញ្ញាអុកឡុកផ្សេងៗគ្នា ដែលធ្វើឱ្យប្រព័ន្ធមានបញ្ហាអាស្រ័យលើអថេរ។

មេរោគនេះឆាប់ផ្ដល់ផលប៉ះពាល់ដល់កុំព្យូទ័រលឿនណាស់ ហើយវាប្រើ file infectors ឬ boot infectos ដើម្បីវាយប្រហារ boot sector ហើយដំណើរការ executable file ដំណាលគ្នា។ មេរោគនេះ បង្កផលប៉ះពាល់ខ្លះ ទោះបីអាចសម្អាតវា ហើយក៏ដោយ ប៉ុន្តែ boot sector មិនត្រូវបានសម្អាត។ ដំបូងឡើយមេរោគ Multipartitle Virus នេះមានឈ្មោះថា Ghostball virus ដែលរកឃើញដោយលោក Fridrik Skulason នៅឆ្នាំ១៩៨៩។ អ្នកជំនាញកុំព្យូទ័រមានការប្រុងប្រយ័ត្នវាខ្លាំងជាប្រភេទមេរោគផ្សេងៗទៅទៀត។ ដើម្បីការពារវា៖

-ត្រូវដំឡើង កម្មវិធីកម្ចាត់មេរោគសមត្ថភាពខ្ពស់គួរឱ្យទុកចិត្ត

-មិនត្រូវបើកឯកសារដែលគេផ្ញើភ្ជាប់តាមអ៊ីមែល ( attachment ) ឬទាញយក ( download ) ឯកសារដែលមិនគួរឱ្យទុកចិត្ត និងធ្វើបច្ចុប្បន្នភាពលើកម្មវិធីកម្ចាត់មេរោគឱ្យបានទៀតទាត់។

## Polymorphic

Polymorphic ឬ Polymorphic infection ជាប្រភេទវីរុសចម្លងខ្លួនយ៉ាងរហ័ស និងផ្លាស់ប្ដូរឈ្មោះផ្សេងៗគ្នារាល់ពេលចម្លង ដើម្បីបំភាន់ភ្នែកអ្នកប្រើ និងគេចពីការចាប់ខ្លួនដោយកម្មវិធី។ មេរោគនេះត្រូវបានបង្កើតដោយកំណត់ឱ្យប្រើវិធីសាស្ត្រ encrypt នៅពេលចម្លងខ្លួនម្ដងៗ។

ដូច្នេះរាល់ពេលចម្លងខ្លួនម្ដងៗ វានឹងមានទម្រង់ផ្សេងៗគ្នារាប់រយ ឬរាប់ពាន់ដែលធ្វើឱ្យកម្មវិធីកម្ចាត់មេរោគពិបាកក្នុងការកំណត់អត្តសញ្ញាណ និងពិបាកលុបចេញពីកុំព្យូទ័រ ព្រោះកម្មវិធីភាគច្រើនស្គាល់ និងអាចចាប់បានតែកូដមេរោគជាក់លាក់ប៉ុណ្ណោះ។ អ្នកអភិវឌ្ឍកម្មវិធី ( Developer ) ដែលបង្កើតកម្មវិធីកម្ចាត់មេរោគត្រូវសរសេរបន្ថែមកូដជាច្រើនទៀតដើម្បីបង្ក្រាបមេរោគប្រភេទនេះ។



# Resident Virus

វីរុស Resident គឺជាប្រភេទមេរោគកុំព្យូទ័រមួយ ដែលក្រោយពីឆ្លងចូលទៅប្រព័ន្ធនឹងចម្លង និងលាក់ខ្លួននៅក្នុងអង្គចងចាំនៃកុំព្យូទ័រ។ មេរោគនេះ នឹងធ្វើឱ្យប៉ះពាល់ដល់ឯកសាររបស់អ្នកអាស្រ័យលើគោលបំណងផ្សេងៗរបស់អ្នកសរសេរកម្មវិធី។ មេរោគ Resident Virus ត្រូវបានបែកចែកជាពីរទៀតគឺ fast ifectors និង slow infectors។

Fast infectors អាចធ្វើបញ្ហាដល់កុំព្យូទ័រឆាប់រហ័ស តែក៏ងាយកត់ចំណាំដែរដោយសាររោគសញ្ញារបស់វា ចំណែក Slow infectors គឺមានលទ្ធភាពពង្រាយខ្លួនកាន់តែច្រើន និងធំឡើងៗ ពីព្រោះវាមិនងាយត្រូវបានគេរកឃើញ គឺត្រូវការពេលវេលាយូរ។ ឥទ្ធិពលម៉្យាងទៀតរបស់ Resident Virus នៅពេលឆ្លងចូលកុំព្យូទ័រហើយ វានឹងបិទសមត្ថភាពរបស់កម្មវិធីកម្ចាត់មេរោគដែលមានខ្សោយ ហើយត្រូវមាន tool ពិសេសដែលមានសមត្ថភាពពន្លាវីរុសនោះពីអង្គចងចាំបាន។



# Web Scripting

វែបសាយជាច្រើនដំណើរការបានដោយភាសាកូដស្មុគស្មាញ ដើម្បីធ្វើឱ្យមាតិកាទទួលបានការចាប់អារម្មណ៍។ ឧទាហរណ៍៖ ការបង្ហាញចេញជាទម្រង់លេង (Play) វីដេអូអនឡាញនៅលើ Browser គឺត្រូវការភាសាកូដជាក់លាក់ ត្រឹមត្រូវដើម្បីដំណើរការផ្តល់ទាំងប្រភេទវីដេអូលេងដោយខ្លួនឯង និងលេងតាម player interface។

ដូច្នេះ កូដទាំងនោះពេលខ្លះអាចជះផលមិនល្អ ដោយបង្កើតជាវីរុសបង្កផលប៉ះពាល់ដល់កុំព្យូទ័រ ឬឆ្លងចេញពីវែបសាយ។ គេហទំព័រមួយចំនួនត្រូវបានបង្កើតភ្ជាប់ជាមួយឥទ្ធិពលអាក្រក់ដល់កុំព្យូទ័របានដោយសារបង្កើតដោយគ្មានចំណេះដឹងច្បាស់លាស់ពាក់ព័ន្ធ Webmaster៕




ដំណើរការរហ័ស
ចេញផ្សាយរៀងរាល់ខែ
អាចដំណើរការបានជាលក្ខណៈ Online & Offline
មើលបានគ្រប់ទីកន្លែង គ្រប់ពេល
IT City Magazine
iOS . Android . PC




# បង្កើតរូបភាព Animated Vector នៅក្នុង Adobe Illustrator និង Photoshop

រូបតំណាង Animating vector និងការរចនា ធ្វើឡើងដោយងាយស្រួលជាមួយកម្មវិធី Adobe Illustrator ។ ការបង្កើតរូបតំណាងងាយៗ ហើយយកពួកគេចូលទៅក្នុង Photoshop សម្រាប់បង្កើតជា GIF ងាយៗ។ ពេលនេះយើងនឹងបង្កើតរូបតំណាងដែលមានចលនាចំនួនបីរូប ហើយស្វែងរកបច្ចេកទេសសម្រាប់បង្កើតរូបភាពដោយរលូន និងចលនាងាយៗ ។

## 1. គូរស្រោមសំបុត្រ

### ជំហានទី 1

បង្កើត New Document នៅក្នុង Adobe Illustrator។ ដោយប្រើ Rectangle Tool (M) គូរចតុកោណកែងដែលមានបន្ទាត់ពណ៌ខៀវ ហើយធ្វើការជ្រើសរើសចំណុច anchor ខាងក្រោមទាំងពីរ ដោយប្រើ Direct Selection Tool (A) បន្ទាប់មកទាញ Live Corners ចូលក្នុងដើម្បីកាត់ជ្រុងទាំងពីរ។ ប្រើ Pen Tool (P) ដើម្បីគូរគំនូសបន្ទាត់ពណ៌ខៀវដែលកំណត់ការបើកស្រោមសំបុត្រ។



### ជំហានទី 2

គូរបន្ទាត់ពីរទាំងជាមួយ Pen Tool ឬក៏ Line Segment Tool (/) ដែលជួបគ្នានៅក្បែរចំនុចកណ្តាលនៃស្រោមសំបុត្រ។ Expand គំនូសរបស់អ្នកនៅក្រោម Object ហើយប្រើ Shape Builder Tool (Shift-M) ដើម្បីជ្រើសរើសផ្នែកដែលមិនជាទីចាប់អារម្មណ៍នៃបន្ទាត់ចេញពីចតុកោណកែងតាមលំដាប់ដើម្បីលុបវា។ នេះជារូបរាងមូលដ្ឋានរបស់រូបស្រោមសំបុត្រ។



### ជំហានទី 3

Copy (Control-C) និង Paste (Control-V) ស្រោមសំបុត្រដែលបានរចនា ហើយគូររូបត្រីកោណចេញពីជ្រុងខាងលើទៅជ្រុងខាងលើសម្រាប់បើកស្រោមសំបុត្រ។ ជ្រើសរើសត្រីកោណស្របពេលដែលចុច Key Alt ហើយទាញចេញក្រៅត្រួតគ្នានៃរូបត្រីកោណ។ Rotate (R) វាជុំវិញដើម្បីបង្កើតគំរបស្រោមសំបុត្រ ហើយកំណត់ពណ៌ទៅជាពណ៌ខៀវក្រម៉ៅ។ សម្រាប់អត្ថប្រយោជន៍នៃការចង្អុលបង្ហាញបន្ទាត់ដែលបាត់ចេញពីការរចនាខាងក្រោម ប៉ុន្តែវានឹងត្រូវបានប្រើនៅក្នុងជំនាន់ចុងក្រោយ។



### ជំហានទី 4

ពេលនេះយើងគួរតែមានរូបស្រោមសំបុត្រពីរ៖ មួយបើក ហើយមួយទៀតបិទ។ គោលដៅគឺដើម្បីបង្កើតស្រោមសំបុត្រជាច្រើនដែលជាការភ្ជាប់ចន្លោះរវាងស្រោមសំបុត្របិទ និងស្រោមសំបុត្របើកសម្រាប់ចលនាចុងក្រោយ។ Group (Control-G) សមាសធាតុទាំងអស់របស់ស្រោមសំបុត្រនីមួយៗ។



## 2. បង្កើតទម្រង់ខុសគ្នារបស់ស្រោមសំបុត្រ

### ជំហានទី 1

Duplicate ស្រោមសំបុត្រដែលបើក ហើយប្រើ Direct Selection Tool ដើម្បីទុកចន្លោះត្រីកោណខាងលើជាមួយចំនុច anchor ផ្នែកខាងលើ និងទាញវាចុះក្រោមរហូតដល់វាស្មើរតែគ្របដណ្តប់ពេញលើត្រីកោណពណ៌ក្រម៉ៅជាង។ Duplicate ក្រុមស្រោមសំបុត្រនេះនិងទាញចំនុចទាបជាងគេរបស់ត្រីកោណពណ៌ភ្លឺឡើងលើបន្តិច ដូចនេះស្រោមសំបុត្រមើលទៅហាក់ដូចជាបើកបន្តិចហើយ។ ត្រូវបន្តធ្វើស្រោមសំបុត្រនីមួយៗដូចៗគ្នា ហើយផ្លាស់ទីរូបត្រីកោណឡើងលើរហូតដល់វាត្រលប់មកចំនុចចាប់ផ្តើមម្តងទៀត ។



### ជំហានទី 2

ជាចុងក្រោយ រូបបញ្ចូលស្រោមសំបុត្របិទ និងស្រោមសំបុត្របើក ពេលនេះមានស្រោមសំបុត្រប្រាំបួនសម្រាប់រូបតំណាងដែលមានចលនា។ លោកអ្នកអាចពិនិត្យមើលការដាក់រូបត្រីកោណ និងចំណុច anchor របស់វា នៅខាងក្រោម។ ត្រូវប្រាកដថាស្រោមសំបុត្រនីមួយៗ បានជាក្រុមដោយឡែកពីគ្នា ដូច្នេះវាងាយស្រួលក្នុងការទាញចូល Adobe Photoshop តាមក្រោយ។



## 3. បង្កើតសំបុត្រ

### ជំហានទី 1

គូរចតុកោណកែងពណ៌លឿងខ្ចី ហើយ Copy និង Paste វាពីលើរូបស្រោមសំបុត្រនីមួយៗ។ គោលដៅគឺដើម្បីមានចតុកោណកែងផ្លាស់ទីឡើងលើក្នុងដែលវាបើក។ យើងសម្រេចយកចតុកោណកែងសរុបចំនួនប្រាំពីរសម្រាប់ការរចនានេះ។



### ជំហានទី 2

ជ្រើសរើសស្រោមសំបុត្រដំបូង និងចតុកោណកែងដែលត្រួតគ្នា។ ប្រើ Shape Builder Tool ជ្រើសរើសចំណែករបស់ចតុកោណកែងពណ៌លឿងដែលប្រសព្វគ្នាជាមួយស្រោមសំបុត្រខាងក្នុង។ លុបចោលផ្នែកមិនត្រូវការរបស់ចតុកោណកែងពណ៌លឿង ដូចនេះអ្នកអាចលប់ត្រីកោណតូចៗរបស់ចតុកោណកែងពណ៌លឿង។ ធ្វើឡើងវិញនូវបច្ចេកទេសដដែលទៅលើស្រោមសំបុត្រផ្សេងទៀត។



### ជំហានទី 3

បន្តការកំណត់រូបសំបុត្រពណ៌លឿងសម្រាប់ស្រោមសំបុត្រនីមួយៗ។ អ្នកអាចឃើញអ្វីដែលសំបុត្រមើលទៅដូចជាមួយស្រោមសំបុត្រដែលត្រូវគ្នាដូចខាងក្រោម ។



### ជំហានទី 4

គូរចតុកោណកែងស្តើងមួយចំនួនដើម្បីបន្លំធ្វើជាបន្ទាត់អក្សរនៅលើសំបុត្រ។ Align និង Distribute ចតុកោណកែងនៅក្នុង Align panel ។ បន្ទាប់មក Unite ពួកវានៅក្នុង Pathfinder panel។



### ជំហានទី 5

ដាក់បណ្តុំជាច្រើនរបស់ចតុកោណកែងទៅលើស្រោមសំបុត្រនីមួយៗ។ ចំណាំពីរបៀបបង្ហាញសំបុត្រច្រើនបន្ទាត់ផ្សេងគ្នា ពេលនេះយើងដាក់សំណុំនៃចតុកោណកែងប្រាំមួយនៅលើស្រោមសំបុត្រប្រាំបួន។



### ជំហានទី 6

ជ្រើសរើសរូបសំបុត្រ និងចតុកោណកែង ហើយប្រើ Shape Builder Tool ជ្រើសរើសផ្នែកដែលមិនត្រូវការរបស់ចតុកោណកែងនីមួយៗនិងលុបវាចោល។ ធ្វើជំហាននេះឡើងវិញសម្រាប់គ្រប់ស្រោមសំបុត្រទាំងអស់។



### ជំហានទី 7

Group ស្រោមសំបុត្រនីមួយៗចូលគ្នា និងសមាសធាតុរបស់វា ដូចនេះនឹងមានក្រុមដាច់ដោយឡែកចំនួនប្រាំបួន។ ពេលនេះយើងត្រៀមដើម្បីដាក់ចលនាឱ្យការរចនា។



## 4. ចលនាស្រោមសំបុត្រ

### ជំហានទី 1

បើក Adobe Photoshop ហើយបង្កើត New Document ដែលមានទំហំ 72 dpi (មិនចាំបាច់ប្រើកម្រិតភាពច្បាស់វាធំនោះទេ ព្រោះយើងមិនត្រូវការពង្រីនចេញ) 250 px ទទឹង និងកម្ពស់ 300 px។ លោកអ្នកអាចបង្កើតឯកសារធំ ឬតូចជាងប្រសិនបើអ្នកត្រូវការ បន្ទាប់មកកាត់ឯកសារនៅពេលដែលអ្នកត្រូវការ។

នៅក្នុង Adobe Illustrator ត្រូវ Copy ក្រុមស្រោមសំបុត្រនីមួយៗ ហើយ Paste វាទៅក្នុងឯកសារ Adobe Photoshop។ ប្រសិនបើអ្នកត្រូវការប្តូរទំហំរូបភាពដោយគ្មានការបាត់បង់គុណភាព paste ក្រុមនីមួយៗក្នុង Smart Object។ ប្រសិនជាពេញចិត្តទំហំហើយ Paste វាទៅក្នុងស្រទាប់ថ្មីដូច Pixels។




### ជំហានទី 2

ត្រូវប្រាកដថា object នីមួយៗ នៅស្រទាប់បន្តគ្នា ។ បន្ថែមពីលើនេះទៀត នឹងត្រូវការជ្រើសរើសស្រទាប់ទាំងប្រាំបួនហើយ Align វាទៅផ្នែកកណ្តាល និងជ្រុងខាងក្រោម។



### ជំហានទី 3

បើក Timeline panel ហើយបង្កើត New Frame Animation។ ចាប់ផ្តើមជាមួយស្រទាប់ស្រោមសំបុត្របិទ (លាក់ផ្សេងៗទៀត) ហើយបង្កើត New Frame កំណត់ចន្លោះពន្យាពេលទៅ 0.1 second។ សម្រាប់ frame នីមួយៗ មិនបានលាក់នៅស្រទាប់បន្ទាប់នោះទេ ហើយលាក់ស្រទាប់មុនរហូតដល់ស្រោមសំបុត្របើក ។ បន្ទាប់មកកំណត់ការពន្យារពេល 0.2–0.5 seconds ។ ធ្វើការបង្ហាញ និងលាក់ស្រទាប់ឡើងវិញ ប៉ុន្តែនៅពេលចូលទៅលំដាប់បញ្ច្រាសស្រោមសំបុត្រត្រូវបិទម្តងទៀត។ ត្រូវប្រាកដថាវាដំណើរការវិលជុំ "Forever" ដូចនេះរក្សាចលនាបើក និងបិទ។




### ជំហានទី 4

ធ្វើឡើងវិញហើយចុចលើ Play នៅលើ Timeline panel ដើម្បីមើល gif វិលជុំ។ អ្នកអាចកែសម្រួលការពន្យារពេលសម្រាប់បង្ហាញឱ្យឃើតជាងមុន ឬលឿនឱ្យបានល្អ ការផ្លាស់ប្តូរតាមរយៈការបិទ ឬបើកស្រោមសំបុត្រគឺបានមើលឃើញនៅក្នុង Timeline panel។ ចាប់ផ្តើមផ្លាស់ទីនៅលើរូបតំណាងផ្សេងទៀត ហើយបន្ថែមបច្ចេកទេសរបស់ចលនា។



## 5. គូររូប Chat Icon

### ជំហានទី 1

ត្រលប់ទៅ Adobe Illustrator ទាំងនៅក្នុងឯកសារថ្មី ឬនៅលើស្រទាប់ថ្មី គូររង្វង់មួយដោយប្រើ Ellipse Tool (L) បន្ទាប់មកត្រួតរង្វង់លើគ្នាជាមួយរូបត្រីកោណតូចហើយ Unite រូបទាំងពីរចូលគ្នា នេះជាមូលដ្ឋាននៃពពុះ chat។ គូររូបរង្វង់អេលីបចំនួនបី ដើម្បីប្រើជាចលនាសំបុត្រ។



### ជំហានទី 2

Copy និង Paste ពពុះ chat ហើយ Reflect វាពីលើ Vertical Axis។ ផ្លាស់ប្តូរពណ៌របស់ពពុះទីពីរទៅជាពណ៌ក្រម៉ៅ។ Scale អេលីបចុះក្រោម ដូចនេះវានឹងនៅក្នុងពពុះ chat។ បន្ទាប់ទៅទៀតយើងនឹងបន្ថែមអក្សរ។




### ជំហានទី 3

គូរ ឬក៏សរសេរខាងក្រៅដោយទម្រង់ពាក្យដូចជា "hey" និង "hi" ទាំងការប្រើម៉ូតអក្សរសរសេរដៃ ឬការគូរអក្សរនីមួយៗជាមួយ Paintbrush Tool (B) ប្រើជក់ calligraphic ដែលមានស្រាប់។ ត្រូវប្រាកដថាអក្សរ ឬគំនូរបានបំលែងទៅជា objects និងតួអក្សរនីមួយៗបានផ្តាច់ object។



### ជំហានទី 4

វាយបញ្ចូល ឬគូរជាសញ្ញាជារូបអក្សរដែលបង្ហាញពីអារម្មណ៍នៅក្នុងពពុះ chat។ នេះជាការឧទាហរណ៍ អ្នកអាចគូរសញ្ញាបញ្ជាក់អារម្មណ៍ជំនួសវិញ។ ប្រសិនបើរូបតំណាង chat និងម៉ូដទាំងអស់សម្រេចតាមអ្នក។ ជាសរុបមកមាន 14 សមាសធាតុកាត់ផ្ដាច់ដូចខាងក្រោម : អេលីបបី អក្សរប្រាំ ពពុះ chat ពីរ និងបួន objects ដែលបង្កើតសញ្ញាបង្ហាញអារម្មណ៍។ រូបនីមួយៗនឹង Copied ហើយ Pasted ទៅក្នុងឯកសារថ្មី នៅក្នុង Adobe Photoshop ដោយស្រទាប់ដោយឡែក។




## 6. ចលនា Chat Icon

### ជំហានទី 1

នៅក្នុង Adobe Photoshop ត្រូវ Paste សមាសធាតុនីមួយៗទាំង 14 icon ចូលទៅឯកសារដែលមានស្រទាប់ថ្មី។ ដាក់បញ្ចូលគ្នាជាក្រុមដូច objects ដូចក្នុងរូបខាងក្រោមក្នុង Layers panel: សមាសធាតុសម្រាប់ពាក្យនីមួយៗ សញ្ញាបង្ហាញពីអារម្មណ៍ អេលីប និងពពុះ chat។ រក្សាការរៀបចំឯកសារ និងបង្កើតជាចលនា GIF គ្រប់ពីលើទាំងអស់ដោយងាយស្រួល។



# Q&A

វិធីសាស្ត្រដើម្បីប្រើប្រាស់កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់របស់ Google ដើម្បី Sync ពាក្យសម្ងាត់របស់អ្នកគ្រប់ទីកន្លែង

របៀបក្នុងការ Mute ផ្ទាំង Individual Brower នៅក្នុងកម្មវិធី Chrome, Safari និង Firefox

## សំណួរ

ឈ្មោះ: ឧត្តម រចនា
rachana@gmail.com

ជម្រាបសួរ! ខ្ញុំបាទឈ្មោះ ឧត្តម រចនា ជាប្រិយមិត្តអ្នកអានរបស់ទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ ហើយរាល់ថ្ងៃខ្ញុំកំពុងសិក្សាផ្នែកកុំព្យូទ័រនៅក្នុងសាកលវិទ្យាល័យឆ្នាំទីពីរនៅក្នុងរាជធានីភ្នំពេញ។ នៅពេលនេះប្អូនមានចម្ងល់មួយចំនួនចង់សួរខាងបងឱ្យជួយបកស្រាយ។ សំណួរទី១៖ តើមានវិធីសាស្ត្រអ្វីដើម្បីប្រើប្រាស់កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់របស់ Google ដើម្បី Sync ពាក្យសម្ងាត់របស់អ្នកគ្រប់ទីកន្លែង? សំណួរទី២៖ សូមបងជួយពន្យល់ពីរបៀបក្នុងការ Mute ផ្ទាំង Individual Brower នៅក្នុងកម្មវិធី Chrome, Safari និង Firefox? សំណួរទី៣៖ តើធ្វើដូចម្តេចដើម្បីផ្លាស់ប្តូរការបង្ហាញភាសានៅក្នុងប្រព័ន្ធប្រតិបត្តិការ Windows 10។ សូមបងជួយបង្ហាញដល់ប្អូនដោយអនុគ្រោះ និងសូមអរគុណចំពោះការចែករំលែកនេះ។

## ចម្លើយ

សួស្តីប្អូន ឧត្តម រចនា! ជាបឋមទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យានិងទីក្រុងទូរស័ព្ទសូមអរគុណដល់ប្អូនក៏ដូចជាប្រិយមិត្តអ្នកអានផ្សេងទៀតដែលតែងតែគាំទ្រទស្សនាវដ្តីរបស់យើងកន្លងទៅនេះ ហើយក៏សូមអរគុណជាខ្លាំងចំពោះសំណួរប្អូនដែលបានសួរមកខាងបងដែលសំណួរនេះគឺពិតជាសំណួរដ៏ល្អ និងថ្មីៗក្តៅៗថែមទៀត។ ដូច្នេះដើម្បីធ្វើការដោះស្រាយនូវបញ្ហាដែលប្អូនបានជួបប្រទះដូចនេះយើងខ្ញុំដែលជាក្រុមការងារក្នុងទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យា និងទីក្រុងទូរស័ព្ទសូមធ្វើការបង្ហាញប្រាប់លម្អិតនៅខាងក្រោមនេះអំពីសំណួរដែលប្អូនចង់ដឹង។

### របៀបក្នុងការប្រើប្រាស់កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់របស់ Google ដើម្បី Sync ពាក្យសម្ងាត់របស់អ្នកគ្រប់ ទីកន្លែង

តើអ្នកដឹងទេថា Google មានកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់ផ្ទាល់ខ្លួន? វាមិនគ្រាន់តែជាពាក្យ




មានចម្ងល់សូមទំនាក់ទំនងមកកាន់យើងខ្ញុំ
facebook: It City Magazine

សម្ងាត់ដែលអាច sync បង្កើតនៅក្នុងកម្មវិធី Chrome browser នោះទេ Google ក៏ផ្តល់ជូននូវ web app, កម្មវិធីទូរស័ព្ទ ដែលអាចដំណើរការជាមួយប្រព័ន្ធប្រតិបត្តិការ Android និងបង្កើតពាក្យសម្ងាត់ដោយស្វ័យ ប្រវត្តិហើយមានអ្នកប្រើប្រាស់មួយចំនួនដែលបានដឹងពីលក្ខណៈពិសេសនេះ។

## វិធីទាំងអស់ដែលអ្នកអាចចូលដំណើរការពាក្យសម្ងាត់របស់អ្នក

ពាក្យសម្ងាត់ដែលបានរក្សាទុករបស់អ្នក អាចចូលដំណើរការបានតាមច្រើនវិធី :

•Chrome នៅលើប្រព័ន្ធប្រតិបត្តិការ Windows, Mac, Chrome OS, និង Linux : កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់អាច syncs ជាមួយនឹង Chrome browser ដូច្នេះវាអាចប្រើប្រាស់បាននៅក្នុង Google Chrome នៅលើគ្រប់ desktop និង laptop។

• Chrome សម្រាប់ប្រព័ន្ធប្រតិបត្តិការ Android, iPhone និង iPad : កម្មវិធីទូរស័ព្ទដៃ Google Chrome ក៏អាច sync ពាក្យសម្ងាត់របស់អ្នក ដូច្នេះអ្នកអាចចូលដំណើរការបាននៅក្នុងកម្មវិធី Chrome ដែលនៅលើប្រព័ន្ធប្រតិបត្តិការ Android, iPhone និង iPad។ មិនទាន់មានការអភិវឌ្ឍបន្ថែមនៅលើកម្មវិធី Safari នៅឡើយទេ ដូចនេះអ្នកត្រូវប្រើកម្មវិធីរុករក Chrome ។

•នៅលើ Web : Google ផ្តល់នូវ web-based interface សំរាប់ពាក្យសម្ងាត់របស់អ្នកនៅ https://passwords.google.com។ អ្នកអាច sign inពីគ្រប់ទីកន្លែងជាមួយនឹងគណនី Google របស់អ្នក។

•នៅលើបណ្តាញទូរស័ព្ទដៃ : នេះក៏ជាគេហទំព័រឆ្លើយតបមួយ ដែលមានន័យថាអ្នកអាចចូលដំណើរការវាពី smartphone បាន។ អ្នកក៏អាចបន្ថែមវេបសាយទៅកាន់ home screen នៃស្មាតហ្វូនរបស់អ្នក copy-pasting ពាក្យសម្ងាត់ពី https://passwords.google.com គ្រប់ពេលដែលអ្នកត្រូវការចូលទៅកាន់កម្មវិធី។

•នៅក្នុងប្រព័ន្ធប្រតិបត្តិការAndroid : Googleទើបតែបានបន្ថែមលក្ខណៈពិសេសដែលមានឈ្មោះថា "Smart Lock for Passwords" សម្រាប់ឧបករណ៍ Android ស្ទើរតែទាំងអស់ដែលជាផ្នែកមួយនៃ Google Play Services update។ ការអភិវឌ្ឍរួមបញ្ចូលជាមួយកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់របស់ Google ដើម្បីចូលទៅកាន់កម្មវិធីដោយស្វ័យប្រវត្តិ។ ឧទាហរណ៍ ប្រសិនបើអ្នកចូលទៅកាន់ Netflix តាមរយៈ Chrome នៅលើ desktop ហើយអ្នកបានរក្សាទុកពាក្យសម្ងាត់របស់ Netflix នៅក្នុងកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់របស់ Chrome។ អ្នកអាចបើកដំណើរការ Netflix នៅលើស្មាតហ្វូន ឬក៏ tablet របស់អ្នកបាន Android នឹងផ្តល់នូវលិខិតសម្គាល់របស់ Netflix របស់អ្នកទៅកាន់កម្មវិធីដែលនឹងអនុញ្ញាតឱ្យអ្នកចូលដំណើរការដោយស្វ័យប្រវត្តិ។




## របៀបក្នុងការចាប់ផ្តើមប្រើប្រាស់កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់របស់ Google

ដើម្បីចាប់ផ្តើមប្រើប្រាស់កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់របស់ Google គ្រាន់តែប្រើកម្មវិធី Google Chrome នៅលើ desktop ស្មាតហ្វូន ឬ tablet របស់អ្នក។ Sign into Chrome ជាមួយនឹងគណនី Google របស់អ្នក។ នៅ Chrome Setting សូមចុចប៊ូតុង "Advanced sync settings" ដើម្បីកំណត់ថា Chrome នឹងចាប់ផ្តើម sync ពាក្យសម្ងាត់។



អ្នកគួរប្រាកដថា Chrome ត្រូវបានកំណត់ដើម្បីរក្សាទុកនូវពាក្យសម្ងាត់របស់អ្នក។ នៅលើអេក្រង់ Chrome setting សូមស្វែងរក “passwords” និងធានាថា “Offer to save your web passwords” បានបើកដំណើរការនូវក្រោម “Autofill and forms”។ អ្នកក៏អាច “Enable autofill to fill out web forms in a single click” ដែលនេះនឹងផ្តល់ឱ្យអ្នកនូវការបំពេញដោយស្វ័យប្រវត្តិ ហើយវាក៏អាចបំពេញនូវសេចក្តីលម្អិតអំពីកាតឥណទាននិងអាសយដ្ឋានរបស់អ្នកបានផងដែរ។




បន្ទាប់មកអ្នកអាចចុចលើ “Manage passwords” តំណរនៅទីនេះ ឬក៏ទៅកាន់ chrome://settings/passwords នៅក្នុង Chrome ដើម្បីចូលដំណើរគ្រប់គ្រង និងមើលបញ្ជីពាក្យសម្ងាត់ដែលបានរក្សាទុករបស់អ្នក។




ដើម្បីរក្សាទុកពាក្យសម្ងាត់ពិតប្រាកដបាន គ្រាន់តែទៅកាន់គេហទំព័រ និង sign in។ Chrome នឹងសួរថាតើអ្នកចង់រក្សាទុកឈ្មោះ និងពាក្យសម្ងាត់របស់អ្នកដែលអ្នកប្រើនៅលើវេបសាយ ហើយអ្នកអាចយល់ស្រប។ លើកក្រោយនៅពេលដែលអ្នកទៅកាន់គេហទំព័រនេះ Chrome នឹងបំពេញដោយស្វ័យប្រវត្តិនូវឈ្មោះនិងពាក្យសម្ងាត់របស់អ្នក។




## បង្កើតពាក្យសម្ងាត់ដោយស្វ័យប្រវត្តិ

Google Chrome បានបន្ថែមនូវលក្ខណៈពិសេសដែលអាចបង្កើតពាក្យសម្ងាត់សម្រាប់អ្នក។ កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់ជាច្រើនរួមទាំង LastPass, 1Password, និង Dashlane ក៏ផ្តល់ជូននូវលក្ខណៈពិសេសនេះដែរ។ ទោះយ៉ាងណា លក្ខណៈពិសេសនេះមិនបានអនុញ្ញាតដោយ default នោះទេ ។ Plug Chrome://flags ទៅកាន់ Chrome’s address bar ហើយចុច Enter ដើម្បីចូលដំណើរការបញ្ជីនៃ flags។ កំណត់ទីតាំង flag “Enable password generation” និងកំណត់ទៅ “Enabled” ។




ពេលក្រោយនៅពេលដែលអ្នកបង្កើតពាក្យសម្ងាត់ Chrome នឹង detect ថាអ្នកកំពុងប្រើ account-creation page និងផ្តល់នូវការបំពេញដោយស្វ័យប្រវត្តិ និងរក្សាទុកពាក្យសម្ងាត់សម្រាប់អ្នក។



អ្នកក៏អាចកែប្រែ flags ផ្សេងទៀតដែលអាចធ្វើឱ្យកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់កាន់តែមានប្រសិទ្ធិភាព ឧទាហរណ៍ អ្នកអភិវឌ្ឍវេបសាយមានសមត្ថភាពដើម្បីសម្គាល់ពាក្យសម្ងាត់ជាមួយនឹងជម្រើស "do not remember" ដែលនឹងធ្វើឱ្យ Chrome មិនចងចាំពាក្យសម្ងាត់របស់អ្នក។ វាមាន flag "Enable force-saving of passwords" ដែលនឹងធ្វើឱ្យ Chrome មិនអើពើហើយនឹងអនុញ្ញាតឱ្យវាចងចាំគ្រប់ពាក្យសម្ងាត់។

## របៀបក្នុងការ Mute ផ្ទាំង Individual Browser នៅក្នុងកម្មវិធី Chrome, Safari និង Firefox



Web pages អាចបន្លឺសំឡេងដោយស្វ័យប្រវត្តិតាមរយៈ HTML5 ទោះបីជាអ្នកបានកំណត់កម្មវិធីជំនួយដូចជា Flash និងកម្មវិធីរុករកផ្សេងទៀតក្នុងការចុចដើម្បីដំណើរការ។ កម្មវិធីរុករកសម័យទំនើបបានបញ្ចូលរួចជាស្រេចនូវការបង្ហាញអំពីផ្ទាំងមួយណាដែលកំពុងដំណើរការសំឡេង។ កម្មវិធីរុករកសម័យទំនើបក៏អាចអនុញ្ញាតឱ្យអ្នកបិទបានដែរ។

### Google Chrome

លក្ខណៈពិសេសនេះគឺជាផ្នែកមួយនៃកំណែរបស់កម្មវិធី Chrome និងមិនតម្រូវឱ្យមានការបើក hidden flags សម្រាប់ប្រើប្រាស់អ្វីនោះទេ។ គ្រាន់តែស្វែងរកផ្ទាំងដែលកំពុងដំណើរការសម្លេង អ្នកនឹងឃើញរូបតំណាង speaker នៅខាងឆ្វេងនៃ "x" នៅលើផ្ទាំង។ សូម Right click លើផ្ទាំងហើយជ្រើសយក "Mute Tab"។ រូបតំណាងសំឡេង និងខ្សែរូបតំណាង speaker បញ្ជាក់ប្រាប់អ្នកថាផ្ទាំងនេះមិនត្រូវបានអនុញ្ញាតឱ្យដំណើរការសំឡេងឡើយ។ Right click លើវាម្តងទៀតហើយជ្រើសយក "Unmute Tab" ដើម្បីផ្លាស់ប្តូរជម្រើសរបស់អ្នក។ អ្នកអាចធ្វើដូចនេះដើម្បីទប់ស្កាត់មុនពេលដែលសម្លេងដំណើរការ។




### Apple Safari

របៀបនេះក៏អាចធ្វើទៅបាននៅក្នុង Safari កម្មវិធី Safari គឺជាកម្មវិធីរុករកដំបូងដែលធ្វើឱ្យលក្ខណៈពិសេសនេះអាចដំណើរការបានសម្រាប់អ្នកប្រើប្រាស់របស់ខ្លួនទាំងអស់។ ដូចនៅក្នុងកម្មវិធី Chrome អ្នកនឹងឃើញរូបតំណាង speaker ទៅខាងឆ្វេងនៃប៊ូតុង "x" នៅលើផ្ទាំងនីមួយៗនៃកម្មវិធីរុករកពេលដែលវាកំពុងដំណើរការសំឡេង។ អ្នកអាចចុចលើរូបតំណាង speaker ដើម្បីបិទសម្លេងនៃផ្ទាំងនោះ និងចុចវាម្តងទៀតដើម្បីបើកវិញ។ អ្នកក៏អាច right click ឬក៏ Ctrl click លើផ្ទាំងហើយជ្រើស "Mute Tab" ដើម្បីបិទផ្ទាំងនៃសំឡេង។ មិនដូចនៅក្នុងកម្មវិធី Chrome ទេ មិនមានវិធីដើម្បីទប់ស្កាត់ជាមុនក្នុងការបិទសំឡេងនោះទេ។ ជម្រើសនេះគឺអាចធ្វើទៅបានតែនៅពេលដែលផ្ទាំងនេះកំពុងដំណើរការសំឡេងទៅហើយ។




### Mozilla Firefox

កម្មវិធី Firefox កំពុងតែស្ថិតនៅក្នុងអភិវឌ្ឍបន្ថែមទៅលើសំឡេងនៅលើផ្ទាំងនេះ។ យោងតាមរបាយការណ៍ លក្ខណៈនេះគួរតែអាចមាននៅក្នុង Firefox 42 ដែលវាជាផ្នែកមួយនៃការពិសោធន៍ចុងក្រោយបំផុត "nightly" របស់កម្មវិធី Firefox។ វាធ្វើការស្រដៀងទៅនឹងកម្មវិធី Safari និង Chrome

ដែរ។ ប្រសិនបើផ្ទាំងមួយកំពុងដំណើរការសំឡេង អ្នកនឹងឃើញរូបតំណាងសំឡេងនៅខាងឆ្វេងនៃប៊ូតុង "x" នៅលើផ្ទាំងនោះ។ អ្នកអាចចុចលើរូបតំណាង speaker នោះដើម្បីបិទសំឡេង ឬ right click ផ្ទាំងកម្មវិធីរុករក និងជ្រើសយក "Mute Tab"។ ដូចកម្មវិធី Chrome អញ្ចឹងដែរកម្មវិធី Firefox អនុញ្ញាតឱ្យអ្នកអាចទប់ស្កាត់ជាមុន មុននឹងសំឡេងដំណើរការគ្រាន់តែ right click លើផ្ទាំង និងជ្រើសយក "Mute Tab"។




## Microsoft Edge

Microsoft Edge យ៉ាងហោចណាស់បានរួមបញ្ចូលការបង្ហាញរូបសំឡេងទៅលើផ្ទាំងនៃកម្មវិធីរុករករបស់ខ្លួន។ មិនដូចជាកម្មវិធីរុករកផ្សេងទៀតទេ ការបង្ហាញរូបសំឡេងទាំងអស់នោះគឺស្ថិតនៅជ្រុងខាងឆ្វេងនៃផ្ទាំង។ Microsoft Edge មិនទាន់ផ្តល់នូវវិធីសម្រាប់បិទសំឡេងនៃផ្ទាំងនោះទេ ហើយវាមិនអាចដំណើរការជាមួយ browser extensions។ Brower extensions ឬ Microsoft នឹងដាក់បញ្ចូលលក្ខណៈពិសេសនេះមកកាន់ Edge នៅថ្ងៃខាងមុខ។




# របៀបក្នុងការផ្លាស់ប្តូរការបង្ហាញភាសា នៅក្នុងប្រព័ន្ធប្រតិបត្តិការ Windows 10




ប្រព័ន្ធប្រតិបត្តិការ Windows 10 អាចផ្លាស់ប្តូរ default language បាន។ ដូច្នេះអ្នកមិនចាំបាច់ព្រួយបារម្ភអំពី default language នៅពេលដែលអ្នកទិញកុំព្យូទ័រឡើយ ប្រសិនបើអ្នកចូលចិត្តប្រើភាសាផ្សេងៗនោះ អ្នកអាចផ្លាស់ប្តូរវាបានគ្រប់ពេលវេលា។

## ការតម្លើងភាសានៅក្នុងប្រព័ន្ធប្រតិបត្តិការ Windows 10

